# សម្ភាសន៍ជាមួយ ណោន កន ភេទប្រុស អាយុ៦២ឆ្នាំ

**មុខងារសម័យខ្មែរក្រហមៈ “យោធា”**

**ស្រុកកំណើតនៅភូមិកោះពាក់ ឃុំបពី ស្រុកវឹនសៃ ខេត្តរតនគិរី**

**រស់នៅភូមិអូរស្មាយ ឃុំអូរស្មាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ ម៉ឹម សុវណ្ណ**

**០១:០៩:៥១**

**៣៦ទំព័រ**

សុវណ្ណៈ ពូដំបូងខ្ញុំសូមជំរាបសួរពូ ខ្ញុំសូមណែនាំខ្លួនឲ្យស្គាល់ខ្ញុំឈ្មោះ សុវណ្ណ ខ្ញុំជាបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំមកថ្ងៃនេះខ្ញុំចុះមកធ្វើការដើម្បីប្រមូលឯកសារដើម្បីសរសេរសៀវភៅមគ្គុទេសស្រុកអន្លង់វែងពូ ចឹងខាងខ្ញុំក៏ចុះមកជួបអ៊ំពូមីងនៅខាងស្រុកត្រពាំងប្រាសាទដែរ ដើម្បីឲ្យបានដឹងពត៌មានមួយចំនួន ថាអន្លង់វែងនិងត្រពាំងប្រាសាទពីមុនក៏ជាតំបន់តស៊ូជាមួយខាងរដ្ឋាភិបាលដែរ ។

កនៈ បាទ ។

សុវណ្ណៈ ចឹងថ្ងៃនេះថ្ងៃទី២២ខែ១២ឆ្នាំ២០១៣ ចឹងជាដំបូងខ្ញុំចង់ឲ្យពូណែនាំខ្លួនថា ពូឈ្មោះអីដែរ?

កនៈ ណោន កន ។

សុវណ្ណៈ ពូអាយុប៉ុន្មានហើយ?

កនៈ អាយុ៦២ ។

សុវណ្ណៈ ពូមានចាំទេ ពូកើតឆ្នាណាដែរ?

កនៈ ខ្ញុំមិនបានចាំឆ្នាំទេ ព្រោះខ្ញុំកូនកំព្រា ខ្ញុំអត់មានម៉ែឪផង ។

សុវណ្ណៈ ពូសព្វថ្ងៃពូធ្វើអីគេ ។

កនៈ ប្រជាជន ។

សុវណ្ណៈ ពូមានធ្វើស្រែចម្ការទេ?

កនៈ បាទ! ធ្វើតើ ធ្វើបានតែបន្តិចបន្តួច ។

សុវណ្ណៈ ចឹងក្រៅពីធ្វើស្រែពូមានធ្វើអីទៀតទេ?

កនៈ អត់មានធ្វើអីទេ ធ្វើស្រែចម្ការនិងដាំដំណាំធម្មតាហ្នឹង ។

សុវណ្ណៈ មានដំណាំអីគេ?

កនៈ មានចេកមានដូង ។

សុវណ្ណៈ ចឹងប្រពន្ធពូឈ្មោះអីដែរ?

កនៈ ឡុង នួន ។

សុវណ្ណៈ មីងអាយុប៉ុន្មានហើយ?

កនៈ អាយុ៥៨ ។

សុវណ្ណៈ ពូរាល់ថ្ងៃមានកូនប៉ុន្មាននាក់?

កនៈ មានពីរនាក់ ។

សុវណ្ណៈ ប្រុសប៉ុន្មាន?

កនៈ ប្រុស១ស្រី១ ។

សុវណ្ណៈ សព្វថ្ងៃមានគ្រួសារអស់ហើយនៅ?

កនៈ មានអស់ហើយ ។

សុវណ្ណៈ កូនប្រុសអាយុប៉ុន្មាន?

កនៈ អាយុ៣០ឆ្នាំហើយ ។

សុវណ្ណៈ ចឹងកូនស្រី?

កនៈ ឆ្នាំម្សាញ់ មួយឆ្នាំរោង មួយឆ្នាំម្សាញ់ ។

សុវណ្ណៈ ចឹងពូថាជាជនជាតិ?

កនៈ បាទ!ជនជាតិ ក្រចក់ ។

សុវណ្ណៈ កាលកូនឈប់រៀនហ្នឹង កូនឈប់រៀនត្រឹមថ្នាក់ទីប៉ុន្មាន?

កនៈ ថ្នាក់ទី៣ ។

សុវណ្ណៈ ចឹងមូលហេតុអីបានជាឈប់រៀនកាលហ្នឹង?

កនៈ កាលហ្នឹងគេមិនមានកើតសាលាទេ សាលាកាលនោះវាទៅឆ្ងាយពីស្រុកត្រពាំងប្រាសាទ ពីមុនមិនមានផ្លូវដូចឥឡូវទេ ពីមុនមានតែផ្លូវដើរណា ។

សុវណ្ណៈ ចឹងការរៀនត្រឹមថ្នាក់ទី៣ហ្នឹងយើងរៀនយ៉ាងម៉េច?

កនៈ មិនដឹងជារៀនយ៉ាងម៉េច សួរតានោះគាត់អ្នកបង្រៀន ។

សុវណ្ណៈ ចឹងយើងរៀនតាមភូមិ?

កនៈ បាទ!រៀនតាមភូមិ ។

សុវណ្ណៈ ពីណាគេជាអ្នកបង្រៀន?

កនៈ តាហួង ។

សុវណ្ណៈ តាហួង ប្រធានភូមិអ្នកបង្រៀន?

កនៈ ហ្នឹងហើយ ។

សុវណ្ណៈ ចឹងអន់មានគ្រូមកពីណាមកបង្រៀនទេ?

កនៈ អត់ទេ ។

សុវណ្ណៈ មានមូលហេតុអីកាលហ្នឹង?

កនៈ កាលនោះមកពីផ្តាច់សមាហរណ៍កម្មនោះ ។

សុវណ្ណៈ យើងមិនទាន់ចូលសមាហរណ៍កម្ម?

កនៈ ចូលហើយ តែកំពង់តែបង្កើតផ្លូវ ។

សុវណ្ណៈ ចឹងកាលហ្នឹងយើងមិនទាន់មានផ្លូវអី សាលារៀនអី?

កនៈ បាទ ។

សុវណ្ណៈ ពូមានបងប្អូនប៉ុន្មាននាក់?

កនៈ ខ្ញុំមានតែម្នាក់ឯង ។

សុវណ្ណៈ ឪពុកម្តាយពូឈ្មោះអី?

កនៈ ឈ្មោះ ថេត ។

សុវណ្ណៈ ឪពុកឈ្មោះ ថេត?

កនៈ ម្តាយឈ្មោះ ថេត ។

សុវណ្ណៈ ឪពុកឈ្មោះអី?

កនៈ យឹង ។

សុវណ្ណៈ ជនជាតិទាំងពីរ?

កនៈ អាមួយជនជាតិលាវ អាមួយខ្មែរ ។

សុវណ្ណៈ ឪពុកជនជាតិ?

កនៈ ជនជាតិខ្មែរ ។

សុវណ្ណៈ ម្តាយ?

កនៈ លាវ ។

សុវណ្ណៈ ចឹងម៉េចពូជាជនជាតិក្រចក់វិញ?

កនៈ នៅភូមិគេ គេដាក់ឈ្មោះជនជាតិគេទៅ ឧទាហរណ៍ថា ខ្ញុំនៅជាមួយខ្មែរចឹង ខ្ញុំជនជាតិទេ បើខ្ញុំនៅជាមួយខ្មែរដាក់ថាជនជាតិខ្មែរចឹង ។

សុវណ្ណៈ ចឹងកំណើតដើមឪពុកពូមិនមែនជនជាតិក្រចក់ទេ?

កនៈ អត់ទេ ខ្មែរទាំងអស់ហ្នឹង តែម៉ែលាវ ។

សុវណ្ណៈ	ចឹងម៉េចបានពូដឹងខ្លួនឯងជាជនជាតិក្រចក់?
កនៈ	បើមានបងប្អូននៅហ្នឹង ។
សុវណ្ណៈ	និយាយពីឪពុកពូបង្កើត?
កនៈ	បាទ!ខ្ញុំមកនៅជាមួយអ៊ំ ។
សុវណ្ណៈ	ពូមានស្រុកកំណើតនៅណា?
កនៈ	នៅរតនគិរី ។
សុវណ្ណៈ	រតនគិរីនៅភូមិណា?
កនៈ	កោះពាក់ ស្រុកវឺនសៃ ។
សុវណ្ណៈ	ឃុំអី?
កនៈ	ឃុំបពី ។
សុវណ្ណៈ	ម៉េចបានដាក់ឃុំបពីវិញ?
កនៈ	ដឹងអីគេអ្នកដាក់ ខ្ញុំចេញមកតាំងពីតូច ។
សុវណ្ណៈ	ស្រុកវឺនសៃ?
កនៈ	បាទ ។
សុវណ្ណៈ	កាលហ្នឹងពូនៅក្មេងមានបានទៅរៀនសូត្រនិងគេទេ?
កនៈ	ខ្ញុំមិនបានរៀនទេ ចូលដល់ក្នុងសម័យប៉ុល ពត នោះគេចាប់បង្ខំឲ្យធ្វើកុមារឈានមុខ ។
សុវណ្ណៈ	តែខ្ញុំចង់និយាយថា សម័យប៉ុល ពត កាលពូនៅក្មេងនៅជាមួយឪពុកពូមានទៅសាលារៀនអីទេ?
កនៈ	ដូចខ្ញុំថា មិញហ្នឹងខ្ញុំកូនកំព្រា កូនកំព្រាទៅពីរនាក់បងប្អូនដល់នេះនៅជាមួយអ៊ំ ។
សុវណ្ណៈ	ចឹងមិញពូថាអត់មានបងប្អូនទេ?
កនៈ	មានពីរបងប្អូនប្រុសមួយស្រីមួយ មិងនិយាយកូនខ្ញុំ ឥឡូវនិយាយពីខ្ញុំម្តង ។
សុវណ្ណៈ	ពូមានបងប្អូនបង្កើត?
កនៈ	មានស្រីម្នាក់ហ្នឹង ។
សុវណ្ណៈ	ចឹងស្រីម្នាក់បងឬប្អូន?
កនៈ	ប្អូន ខ្ញុំបងគេបែកពីវាទៀត ។
សុវណ្ណៈ	ឪពុកពូស្លាប់កាលណាពេលហ្នឹង ឪពុកម្តាយស្លាប់ឆ្នាំណា?
កនៈ	សម័យប៉ុល ពត យកវាយចោលអស់ ។
សុវណ្ណៈ	ខ្មែរក្រហមគេវាយចោល?

កនៈ បាទ ។

សុវណ្ណៈ ម៉េចបានដឹងថា ខ្មែរក្រហមយកវាយចោល?

កនៈ គេបញ្ជូនខ្ញុំទៅស្វាយរៀង មិនដឹងជាគេធ្វើយ៉ាងម៉េចនៅខាងក្រោយទៀត ។

សុវណ្ណៈ ចឹងបានន័យថា ពូបាត់ដំណឹងពីឪពុកម្ដាយពូ?

កនៈ បាទ ។

សុវណ្ណៈ តែកាលមុនខ្មែរក្រហមហ្នឹងពូក្រែងនៅជាមួយពូតើ?

កនៈ នៅជាមួយអ៊ី ។

សុវណ្ណៈ ពេលនៅជាមួយអ៊ីខ្មែរក្រហមចូលមកនៅ?

កនៈ កាលនោះអ៊ីខ្ញុំនៅខាងវៀតណាម គាត់ហៅខ្ញុំទៅនៅនោះ ដល់ហៅខ្ញុំទៅនោះខ្មែរក្រហម វាយខ្ញុំ ថាខ្ញុំក្បត់ឪខ្ញុំក្បត់ ។

សុវណ្ណៈ ចឹងពូចូលជាមួយខ្មែរក្រហមគេចាប់ចូលនៅពេលណាកាលហ្នឹង?

កនៈ ឆ្នាំ៧០ ។

សុវណ្ណៈ កាលហ្នឹងគេឲ្យចូលធ្វើអីគេពូ?

កនៈ កាលហ្នឹងធ្វើកុមារកំព្រា ធ្វើកុមារកំព្រាវែកបាយឲ្យគេ ។

សុវណ្ណៈ កាលហ្នឹងពូអាយុប្រហែលជាប៉ុន្មានហើយ?

កនៈ អាយុ១០ឆ្នាំ ។

សុវណ្ណៈ ចឹងកាលហ្នឹងគេឲ្យចូលខាងទ័ពហើយ?

កនៈ អត់ទេ ចូលកុមារកំព្រាតែតស៊ូណាស់ ។

សុវណ្ណៈ ចូលតស៊ូយើងដឹកជញ្ជូនបាយ ដឹកជញ្ជូនគ្រាប់អីមានខ្លះទេ?

កនៈ អត់មានទេ ។

សុវណ្ណៈ មានតែរត់បាយទេ?

កនៈ បាទ ។

សុវណ្ណៈ ចឹងរត់បាយឲ្យខ្មែរគ្រៀម?

កនៈ បាទ ។

សុវណ្ណៈ ចឹងពេលរត់បាយឲ្យខ្មែរគ្រៀមយើងច្រើនរត់ទៅពេលណាកាលហ្នឹង ទៅសមរភូមិខាងណា កាលហ្នឹង?

កនៈ សមរភូមិខាងក្រោយ ដល់ខាងក្រោយបញ្ជូនទៅមុខទៀត ។

សុវណ្ណៈ ចឹងក្រៅពីការងារហ្នឹងមានធ្វើអីផ្សេងទៀតទេ?

កនៈ	អត់មានធ្វើអីទេ ។

សុវណ្ណៈ	ចឹងក្រោយមកគេឲ្យពូចូលទ័ពពេលណាដែរ?

កនៈ	ទ័ពកាលសម័យ៧៩ហ្នឹង ។

សុវណ្ណៈ	កាលសម័យ៧៥?

កនៈ	៧៥កាលនោះគេឲ្យខ្ញុំមកកងចល័ត ។

សុវណ្ណៈ	ចល័តហ្នឹង ចល័តអីគេ?

កនៈ	ចល័តតំបន់ ។

សុវណ្ណៈ	ពីណាគេអ្នកគ្រប់គ្រងកាលហ្នឹង?

កនៈ	តាធិន ។

សុវណ្ណៈ	ចឹងតាធិន ប្រធានកងចល័តតំបន់?

កនៈ	បាទ ។

សុវណ្ណៈ	តំបន់ណាកាលហ្នឹង?

កនៈ	តំបន់ខាងឥសាន ។

សុវណ្ណៈ	ចឹងយើងច្រើនចល័តទៅខាងណាខ្លះពូ?

កនៈ	ចល័តធ្វើគ្រប់កន្លែងខាងមណ្ឌលគិរីក៏បានខាងស្ទឹងត្រែងក៏បាន ។

សុវណ្ណៈ	ការងារកងចល័តមានធ្វើអីខ្លះ?

កនៈ	វែកដី ធ្វើទំនប់ ។

សុវណ្ណៈ	ប្រធានកងចល័តតំបន់ឈ្មោះ តាធិន?

កនៈ	បាទ!ងាប់បាត់ហើយគ្នា ។

សុវណ្ណៈ	ម៉េចបានដឹងថា គាត់ស្លាប់?

កនៈ	ឡាន បុក ។

សុវណ្ណៈ	ពេលណា?

កនៈ	បុកនៅស្ទឹងត្រែង ។

សុវណ្ណៈ	បុកឆ្នាំណាកាលហ្នឹង?

កនៈ	បុកឆ្នាំទៅឆ្នាំ២០១២ ។

សុវណ្ណៈ	ចឹងពេលខែវស្សាយើងធ្វើអីគេ កងចល័តតំបន់ហ្នឹង?

កនៈ	ខែវស្សាយើងទៅច្រូតទៅ ដកសំណាបស្ទូងទៅ ។

សុវណ្ណៈ	ចឹងកាលពូចូលបដិវត្តខ្មែរក្រហមនៅឆ្នាំ៧០ហ្នឹង ពូចូលទាំងបង្ខំឬគេចាប់ឲ្យចូល?

កនៈ        គេចាប់បន្ទំទេខ្ញុំនោះ ។

សុវណ្ណៈ     គេចាប់បន្ទំយ៉ាងម៉េច?

កនៈ        ចុះយើងអត់មានម៉ែឪគេចាប់បន្ទំនិងឯង បើយើងមានម៉ែឪ ម៉ែឪយើងសុំគេ ។

សុវណ្ណៈ     ចឹងកាលគេចាប់ចូលងហ្នឹងឪពុកម្ដាយពូនៅទេ?

កនៈ        នៅ ។

សុវណ្ណៈ     មិនទាន់ស្លាប់ទេ?

កនៈ        នៅ ។

សុវណ្ណៈ     ចឹងឪពុកម្ដាយថា ម៉េចពេលគេចាប់ចូលទៅ?

កនៈ        មានថាម៉េច មានតែយំ ។

សុវណ្ណៈ     អត់មានតាមជួយយើងយកមកវិញទេ?

កនៈ        កាលនោះហ៊ានណាបើហ៊ានយកមានតែងាប់គាត់ ។

សុវណ្ណៈ     ចឹងពេលចាប់ចូលយើងនៅជាមួយឪពុកម្ដាយឬនៅជាមួយខាងទ័ព?

កនៈ        នៅជាមួយកុមារ ។

សុវណ្ណៈ     នៅជាមួយក្រុមកុមាររបស់ពីទៅ?

កនៈ        បាទ ។

សុវណ្ណៈ     ចឹងនៅក្នុងក្រុមកុមារហ្នឹងភាគច្រើនគេចាប់មកឬចូលខ្លួនឯង?

កនៈ        អត់មានចូលខ្លួនឯងទេ មានតែគេចាប់មក គេចាប់មកច្បាប់កាលហ្នឹងច្បាប់កុំម្មុយនីស្តអត់មានស្ម័គ្រចិត្តទេ ។

សុវណ្ណៈ     ចឹងពូស្គាល់អ្នកចាប់ពូឲ្យចូលមកទេ ចាប់ចូលមកនៅក្រុមកុមារជាមួយទ័ពជាមួយអីគេកាលហ្នឹង?

កនៈ        តាយ៉ាន ។

សុវណ្ណៈ     តាយ៉ាន ហ្នឹងគាត់ជាជនជាតិអីគេ?

កនៈ        ជនជាតិខ្មែរ ។

សុវណ្ណៈ     ម៉េចបានជាពូស្គាល់គាត់ជាអ្នកចាប់បន្ទំ?

កនៈ        ចុះគាត់អ្នកដើរតាមភូមិ មកឃោសនាតាមភូមិ ។

សុវណ្ណៈ     ចឹងតាយ៉ាន ហ្នឹងកាលហ្នឹងគាត់ធ្វើអីគេ?

កនៈ        តាយ៉ាន ខាងភូមិភាគ ។

សុវណ្ណៈ     ភូមិភាគណា?

កនៈ ភូមិភាគឥសាន ។

សុវណ្ណៈ គាត់អ្នកគ្រប់គ្រង?

កនៈ បាទ ។

សុវណ្ណៈ ចឹងគាត់គ្រប់គ្រងភូមិភាគឥសានហ្នឹងតាំងពីឆ្នាំ៧០មក?

កនៈ បាទ!មុនឆ្នាំ៧០ទៀត គាត់នោះ ។

សុវណ្ណៈ ចឹងឆ្នាំណាគាត់គ្រប់គ្រងហ្នឹង?

កនៈ ឆ្នាំណាខ្ញុំមិនសូវដឹងដែរ ខ្ញុំនៅក្មេង ចាំខ្លះអត់ខ្លះ ។

សុវណ្ណៈ ចឹងម៉េចបានពូដឹងថា គាត់ជាអ្នកគ្រប់គ្រងភូមិភាគឥសាន?

កនៈ ចុះបើគាត់ជាអ្នកអប់រំឃោសនា ។

សុវណ្ណៈ គាត់អប់រំថា យ៉ាងម៉េច?

កនៈ ថាឲ្យនាំគ្នាតស៊ូ កុំឲ្យខ្មាំងយកទឹកដីខ្មែរ ។

សុវណ្ណៈ គាត់មាននិយាយថា យ៉ាងម៉េចទៀត?

កនៈ គាត់និយាយប៉ុណ្ណឹង មានអីទៀត ខ្ញុំមិនសូវចាំដែរ ។

សុវណ្ណៈ ពូមានបានទៅរៀនទៅសូត្រជាមួយគេទេ?

កនៈ អត់ទេ ។

សុវណ្ណៈ ចឹងគាត់អប់រំតាមលក្ខណៈរបៀបយ៉ាងម៉េច គាត់មកនិយាយមួយក្រុមគ្នាយើងឬហៅមកនិយាយទាំងអស់គ្នា?

កនៈ ហៅមកទាំងអស់ កុមារមានប៉ុន្មានហៅមកមាន២០០ទៅ៣០០នាក់ទៅប្រជុំមួយព្រឹកទៅហើយបានបែកចែកឲ្យទៅរែកបាយឲ្យគេ ។

សុវណ្ណៈ ចឹងនៅក្នុងក្រុមពូមានក្មេងៗប្រហែលជាប៉ុន្មាននាក់?

កនៈ មាន២០០នាក់ ។

សុវណ្ណៈ ភាគច្រើនក្មេងទាំងអស់ហ្នឹងមកពីខាងណា?

កនៈ មកពីគ្រប់ខេត្ត ។

សុវណ្ណៈ គ្រប់ខេត្តហ្នឹង តែយើងសង្កេតឃើញថា ក្មេងៗហ្នឹងភាគច្រើនមកពីខាងភូមិភាគឥសានឬមកពីខាងបូព៌ាមកពីខាងនិរតីឬឧត្តរឬបស្ចឹមពូ?

កនៈ ខាងខ្ញុំក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ស្វាយរៀង ព្រៃវែង ។

សុវណ្ណៈ ចឹងក្មេងៗច្រើនអាយុចន្លោះពីប៉ុន្មានទៅប៉ុន្មាន?

កនៈ	កាលហ្នឹងអាយុ១០ឆ្នាំអាយុ៧ទៅ៨ឆ្នាំតូចៗអាយុ១០ខ្ញុំមិនសូវចាំ   ខ្ញុំច្រើនរត់ទៅផ្ទះនឹកឃើញម៉ែ ។

សុវណ្ណៈ	ចឹងពូសាហ្នឹងខស្សហ៍រត់ទៅផ្ទះពេលគេចាប់ចូលមកធ្វើការជាមួយគេ ចឹងខស្សហ៍រត់ទៅផ្ទះទៅលេងឪពុកម្ដាយដែរ?

កនៈ	រត់នឹកម៉ែឪរត់ចោលតែម្ដង ។

សុវណ្ណៈ	ចឹងពេលនឹកឪពុកម្ដាយនឹកបងប្អូនយើងរត់ចេញពីក្រុមមកលេងឪពុកម្ដាយទៅ?

កនៈ	បាទ ។

សុវណ្ណៈ	ចឹងគេមានថាម៉េច ពេលយើងរត់មកលេងម្ដងៗ?

កនៈ	គេចាប់យកទៅវិញ ។

សុវណ្ណៈ	ចឹងពេលគេចាប់យកទៅវិញ គេមានធ្វើបាបយើងខ្លះទេ?

កនៈ	ធ្វើបាបនិងបានគេឲ្យខ្ញុំធ្វើទ័ពហ្នឹង ។

សុវណ្ណៈ	ចឹងពូខស្សហ៍ទៅលេងឪពុកម្ដាយទេ?

កនៈ	បាទ!ខ្ញុំនឹកម៉ែឪខ្ញុំ ។

សុវណ្ណៈ	ក្នុងមួយខែយើងរត់ទៅលេងឪពុកម្ដាយប៉ុន្មានដង?

កនៈ	អត់មួយខែទេ ជួនកាលកន្លះឆ្នាំទៅម្ដង ។

សុវណ្ណៈ	ចឹងកន្លះឆ្នាំទៅម្ដង?

កនៈ	បាទ!ទៅអត់មានសុំគេទេ នឹកឃើញសុំក៏មិនបានដែរ ចឹងយើងរត់ទៅលេង ។

សុវណ្ណៈ	ចឹងពូមានដែលសុំគេទេ?

កនៈ	សុំគេមិនឲ្យ ។

សុវណ្ណៈ	ពូសុំគេថាម៉េចកាលហ្នឹង?

កនៈ	គេថា មិនឲ្យ គេថាអូនឯងកូនកំព្រាទៅធ្វើអី ខ្ញុំទៅលេងបងប្អូនខ្ញុំម៉ែខ្ញុំស្លាប់អស់ហើយខ្ញុំរត់ញឹកពេក គេឲ្យខ្ញុំធ្វើទាហានទៅ ធ្វើទ័ពនៅអូសកាំភ្លើង ។

សុវណ្ណៈ	ចឹងពូចូលធ្វើទ័ពនៅឆ្នាំណា?

កនៈ	ឆ្នាំ៧៥ ។

សុវណ្ណៈ	ចឹងពូថា នៅកងចល័តតំបន់សិនបានចូលធ្វើទ័ពមុនឬយើងចូល?

កនៈ	ធ្វើទ័ពមុន ។

សុវណ្ណៈ	ចឹងចូលធ្វើទ័ពមុន?

កនៈ បាទ!ចូលធ្វើទ័ពបានដកពីទ័ពបានមកចូលកងចល័ត ពេលគេចំរាញ់ចេញពីសមរភូមិឲ្យមកធ្វើកងចល័តវិញ ។

សុវណ្ណៈ ចឹង៧៥ដំបូងគេឲ្យយើងចូលទ័ព?

កនៈ បាទ ។

សុវណ្ណៈ ចឹងចូលទ័ពហ្នឹងយើងចូលជាមួយខាងណា ខាងកងពលណាពូមានចាំទេ កាលឆ្នាំ៧៥ហ្នឹង?

កនៈ ជាមួយតា០៥ ។

សុវណ្ណៈ តា០៥ជាមួយកងពល៨០១ហ្នឹង?

កនៈ បាទ!៨០១ ។

សុវណ្ណៈ ចឹងពូចូលធ្វើទ័ពបានប៉ុន្មាន?

កនៈ បានរយៈពេល២ឆ្នាំ ។

សុវណ្ណៈ ចឹងចូលបាន២ឆ្នាំឆ្នាំ៧៧គេដកពីទ័ពមកធ្វើកងចល័តវិញ?

កនៈ បាទ ។

សុវណ្ណៈ មានមូលហេតុអីបានគេដកពីទ័ពមកខាងកងចល័តវិញ?

កនៈ ព្រោះកាលហ្នឹងគេចំរាញ់ពីខ្សោយមកខ្លាំង យកពីខ្លាំងមកខ្សោយ ។

សុវណ្ណៈ ពីខ្សោយមកខ្លាំង ពីខ្លាំងមកខ្សោយយ៉ាងម៉េចខ្ញុំមិនយល់?

កនៈ គេយកពីទ័ពមកដាក់កងចល័ត ទ័ពហ្នឹងវាខ្លាំង ខ្សោយហ្នឹងកងចល័តវានៅក្រោយ ។

សុវណ្ណៈ ចឹងម៉េចដឹងថា យើងចូលទ័ពនៅក្នុងកងពល៨០១?

កនៈ កងពិសេស ។

សុវណ្ណៈ នៅក្នុងកងពិសេស កងពល៨០១ហ្នឹង?

កនៈ បាទ ។

សុវណ្ណៈ នៅក្នុងកងពិសេសហ្នឹងពូធ្វើអីខ្លះ កាលចូលទ័ពហ្នឹង?

កនៈ កាលជំនាន់ហ្នឹងយើងវាយអាមេរិចកាំង ។

សុវណ្ណៈ ពូចូលមុន៧៥ទេ ចូលទ័ពហ្នឹង យើងមានទៅវាយជាមួយ លន់ នល់ ខ្លះទេ?

កនៈ វាយតើ ។

សុវណ្ណៈ ចឹងវាយមានន័យថា យើងចូលមុនឆ្នាំ៧៥ទៀតហ្នឹង?

កនៈ ចូលមុនខ្ញុំថា ឆ្នាំ៧០ហ្នឹង កាលហ្នឹងមិនញ្ញុំថាកូនកំព្រាទេចុះ កូនកំព្រាគេមិនឲ្យរែកបាយខ្ញុំរែកបាយ ខ្ញុំខស្បៀងហ៍រត់ទៅផ្ទះ គេបញ្ជូនឲ្យធ្វើទ័ព ចូលទ័ពទៅគេឲ្យមកកងពិសេសនេះទ័ព៨០១ចូលកងពិសេស ។

សុវណ្ណៈ ចឹងពូនៅរត់បាយបានរយៈពេលប៉ុន្មានឆ្នាំ ប៉ុន្មានខែបានគេឲ្យយើងចូលទ័ព?

កនៈ ខ្ញុំរត់បាយបានត្រឹម៥ខែទេ ។

សុវណ្ណៈ ចឹងចូលធ្វើទ័ពហ្នឹង ពេលឡើងទៅសមរភូមិខាងណា កាលពីដំបូង?

កនៈ ខាងណាជុំវិញភ្នំពេញនេះ ផ្លូវភ្នំបន្ទាយលង្វែកអីហ្នឹង ។

សុវណ្ណៈ ចឹងមកវាយនៅខាងលង្វែក?

កនៈ បាទ ។

សុវណ្ណៈ លង្វែកនៅខាងកំពង់ឆ្នាំងហ្នឹង?

កនៈ ហ្នឹងហើយ ។

សុវណ្ណៈ តែមុនយើងឡើងទៅវាយគេមានបង្រៀនខាងទ័ពទេ យោធាយើងមានវិករឹងច្បាស់លាស់ទេកាលហ្នឹង?

កនៈ មានរបស់គេ ។

សុវណ្ណៈ យើងហាត់ទាហានបានប៉ុន្មានខែកាលហ្នឹង បានគេឲ្យយើងកាន់កាំភ្លើងអី?

កនៈ ហាត់បានមួយឆ្នាំ ។

សុវណ្ណៈ គេឲ្យយើងហាត់យ៉ាងម៉េចខ្លះ?

កនៈ ហាត់ក្រាប ហាត់លូន ហាត់វាយផ្គារីក ។

សុវណ្ណៈ វាយផ្គារីកគេវាយយ៉ាងម៉េច?

កនៈ វាយពីក្នុងមកក្រៅ ។

សុវណ្ណៈ ចឹងមានវាយយ៉ាងម៉េចទៀត?

កនៈ វាយពីក្នុងមកក្រៅឲ្យពួកពីក្រៅត្រូវយកទៅពួកថ្មើរជើងនោះ ដូចថាប្អូនឯងចូលទៅមុនដំបូងវាយថ្មើរជើង ដល់វាយថ្មើរជើងប្អូនឯងវាយមិនឈ្នះ បានគេដកទ័ពកងពិសេសនោះវាយផ្គារីកម្តង ដល់វាយផ្គារីកទៅបានប្អូនឯងត្រូវយកពេលចេញពីបន្ទាយហ្នឹង ។

សុវណ្ណៈ ចឹងកាលហ្នឹងពូនៅទ័ពកងពិសេស?

កនៈ បាទ ។

សុវណ្ណៈ ទ័ពកងពិសេសហ្នឹង ភាគច្រើននៅខាងមុខឬខាងក្រោយ?

កនៈ អត់មានមុខអត់មានក្រោយទេ ។

សុវណ្ណៈ ចឹងយើងនៅវាយរបៀបយ៉ាងម៉េច កងពិសេសហ្នឹង?

កនៈ ដូចខ្ញុំថា វាយផ្គារីកវាយគ្រាប់បែក អត់មានប្រើកាំភ្លើងទេ ប្រើគ្រាប់បែក ។

សុវណ្ណៈ ចឹងកងពិសេសមានប្រើកាំភ្លើងទេ?

កនៈ អត់ទេ មានតែគ្រាប់បែក ។

សុវណ្ណៈ ចឹងវាយជាមួយគេប្រើអីគេ?

កនៈ ប្រើគ្រាប់បែកហ្នឹងឯង ។

សុវណ្ណៈ ចឹងប្រើគ្រាប់បែកវាយវិញ?

កនៈ ហ្នឹងហើយ គេមិនឲ្យកាំភ្លើងទេ ។

សុវណ្ណៈ មូលហេតុអីបានជាគេមិនឲ្យកាំភ្លើងយើង?

កនៈ កាលណាយើងយកកាំភ្លើងវាទាក់ទៀមជាមួយគ្រាប់បែក កាលណាយើងកាំភ្លើងរវល់តែបើកសោកាំភ្លើង ទាញគ្រាប់បែកផងវាមិនច្រឡំ ជួនកាលគេចាប់បាន បើគ្រាប់បែកសុទ្ធគេអាចគ្រាប់បែកបណ្ដោយ ត្រូវសម្លាប់ខ្លួនឯងសម្លាប់មិនសម្លាប់អត់ទៅ ។

សុវណ្ណៈ ចឹងគ្រាប់បែកហ្នឹងពេលយើងឡើងទៅម្នាក់ៗកាន់បានប៉ុន្មានគ្រាប់?

កនៈ កាន់បាន៥០គ្រាប់ ។

សុវណ្ណៈ ម្នាក់ឯងកាន់៥០គ្រាប់?

កនៈ បាទ ។

សុវណ្ណៈ យើងស្ពាយសាក់កាដូគ្រាប់បែកហ្នឹងឬយើងមានអីទុក?

កនៈ មានស្ពាយណាអាហ្នឹងយើងដាក់ស្មាគេ តាំងពីចង្កេះមកស្មាគេ ។

សុវណ្ណៈ គេដាក់ជុំវិញចង្កេះគ្រាប់បែកហ្នឹង?

កនៈ ហ្នឹងហើយ ។

សុវណ្ណៈ ដាក់នៅចង្កេះហើយដាក់នៅណាទៀត?

កនៈ ដាក់ខ្វែងចេះមក ។

សុវណ្ណៈ គេមានខ្សែក្រវ៉ាត់គេព្យួរជាមួយគ្រាប់បែក?

កនៈ ហ្នឹងហើយ ។

សុវណ្ណៈ ចឹងយើងក្រវ៉ាត់នេះផង ក្រវ៉ាត់ឆ្វេងក្រវ៉ាត់ស្ដាំ ក្រវ៉ាត់ចង្កេះ ពីស្មាចុះមកក្រោម?

កនៈ មានអាវរបស់គេ អាវពាក់គ្រាប់បែក ។

សុវណ្ណៈ គ្រាប់ហ្នឹងច្រើនគ្រប់អីគេ?

កនៈ គ្រាប់ផ្លែប៉ម ។

សុវណ្ណៈ ប៉ុណ្ណាទៅ?

កនៈ ប៉ុនកដៃ ។

សុវណ្ណៈ ចំនួន៥០គ្រាប់ប៉ុនកដៃច្រើនដែរ?

កនៈ	ច្រើន ធ្ងន់ណាស់ ។

សុវណ្ណៈ	យើងវាយរបៀបយ៉ាងម៉េចគ្រាប់បែកហ្នឹង?

កនៈ	យើងលួនបោកគ្រាប់បែកទៅ យើងចំណាំបន្ទាយចំណាំត្រង់សេវ៉ាទៅ យើងគប់ទៅ បើថាមានរថក្រោះចាំរថក្រោះទៅ បើមានកាំភ្លើងធំចាំលើកាំភ្លើងធំហ្នឹងវាយលើកាំភ្លើងធំទៅ ។

សុវណ្ណៈ	កងពិសេសរបស់ពូមានគ្នាប៉ុន្មាននាក់កាលហ្នឹង?

កនៈ	ជួនកាល១០០នាក់ ។

សុវណ្ណៈ	តែនៅក្នុងក្រុមរបស់ពូមានគ្នាប៉ុន្មាននាក់ កងពិសេសហ្នឹង?

កនៈ	មួយ“គ”មានគ្នា១០០នាក់ ។

សុវណ្ណៈ	១០០នាក់ហ្នឹង ច្រើនមកពីខាងណាខ្លះ?

កនៈ	មានគ្រប់ចំរុះគ្រប់ខេត្ត មានខេត្តកណ្ដាលក៏មាន ខេត្តកំពតក៏មាន និយាយគេដកយកតែម្នាក់ៗទេ មួយខេត្តមួយកងពលហ្នឹង មួយវរសេនាធំគេដកយកតែម្នាក់ៗទេ ។

សុវណ្ណៈ	នៅក្នុងកងពិសេសហ្នឹង ក្នុងមួយវរសេនាធំគេដកយកម្នាក់?

កនៈ	ហ្នឹងហើយ ។

សុវណ្ណៈ	ចឹងគ្រប់កងពលទាំងអស់?

កនៈ	ហ្នឹងហើយ មួយកងពល១០នាក់ ។

សុវណ្ណៈ	ចឹង១០០នាក់ហ្នឹង មកពីគ្រប់កងពលទូទាំងប្រទេសទាំងអស់?

កនៈ	បាទ!ទូទាំងប្រទេស ។

សុវណ្ណៈ	ពីណាគេប្រធានកងពិសេសហ្នឹង?

កនៈ	តាទុំ ងាប់បាត់ហើយ ។

សុវណ្ណៈ	តាទុំ ហ្នឹងជនជាតិអីគេ?

កនៈ	ជនជាតិខ្មែរ ។

សុវណ្ណៈ	មិនមែនជនជាតិភ្នង ជាទំពួន ចារាយណ៍អីទេ?

កនៈ	អត់ទេ ។

សុវណ្ណៈ	ចឹងជនជាតិខ្មែរមកពីខាងណាវិញ?

កនៈ	នៅខេត្តកណ្ដាល ។

សុវណ្ណៈ	ម៉េចបានពូដឹងថា តាទុំ មកពីខេត្តកណ្ដាល?

កនៈ	ព្រោះប្រវត្តិគាត់ដាក់ថានៅខេត្តកណ្ដាល ប្រវត្តិគាត់គេអញ្ជើញពីហ្នឹងមក ។

សុវណ្ណៈ	ចឹងអនុតាទុំ ពីណាគេ?

កនៈ　　តាទុំ ហ្នឹងអនុគាត់តាថាន ។

សុវណ្ណៈ　　តាថាន?

កនៈ　　តាថាន ក៏ងាប់ដែរ ។

សុវណ្ណៈ　　គាត់ស្លាប់ហើយ?

កនៈ　　បាទ ។

សុវណ្ណៈ　　ចឹងតាទុំ?

កនៈ　　តាទុំ ក៏ស្លាប់ ។

សុវណ្ណៈ　　គាត់ស្លាប់នៅពេលណា?

កនៈ　　ឆ្នាំ៧៩ ។

សុវណ្ណៈ　　សម័យ៧៩ពេលយួនវាយចូលហ្នឹង?

កនៈ　　អត់ទេ គេសម្លាប់នៅក្រោយទេ វៀតណាមរំដោះបានហើយ ។

សុវណ្ណៈ　　ចឹងវៀតណាមរំដោះហើយបានគាត់ស្លាប់?

កនៈ　　បាទ ។

សុវណ្ណៈ　　គាត់ស្លាប់ដោយសារអីគេ?

កនៈ　　ស្លាប់ កាលហ្នឹងដោយសារមានទំនាស់គ្នា រឿងជាមួយតា០៥ហ្នឹងឯង គេដកគាត់ចេញ ហើយគាត់បាញ់ខ្លួនឯងចោល ។

សុវណ្ណៈ　　ចឹងតាទុំ បាញ់សម្លាប់ខ្លួនឯងចោល?

កនៈ　　បាទ ។

សុវណ្ណៈ　　ចឹងពេលវៀតណាមរំដោះហើយមានទំនាស់ផ្ទៃក្នុងខាងខ្មែរក្រហមហ្នឹង?

កនៈ　　បាទ ។

សុវណ្ណៈ　　ចឹងតាទុំ សម្លាប់ខ្លួនឯងទៅ?

កនៈ　　ហ្នឹងហើយ ។

សុវណ្ណៈ　　ចឹងតាថាន?

កនៈ　　តាថាន គាត់ស្លាប់ដោយថៃបាញ់ចោល ។

សុវណ្ណៈ　　ថៃបាញ់ចោលឆ្នាំណា កាលហ្នឹង?

កនៈ　　ឆ្នាំ៨១ ។

សុវណ្ណៈ　　មេ៉ចបានថៃបាញ់គាត់ចោល?

កនៈ	កាលនោះថៃបង្កើតខ្មែរក្រហម ថៃក្រហម ខាងបាងកកនោះ មិនចេញមកតស៊ូ ដល់គាត់មកទាក់ទង ប៉ុល ពត នៅប៉ៃលិននេះ ថៃគេបាញ់ទៅ ។

សុវណ្ណៈ	ចឹងតាទុំ ស្លាប់ឆ្នាំណា?

កនៈ	ស្លាប់ប៉ុន្មានទេ វង្វេងវង្វាន់ឆ្នាំ៧៩ ។

សុវណ្ណៈ	តែមកស្លាប់នៅលើភ្នំឬក៏យ៉ាងម៉េច?

កនៈ	តាទុំ ស្លាប់នៅដីខ្មែរ ។

សុវណ្ណៈ	មិនមែនលើភ្នំដងរែកទេ?

កនៈ	អត់ទេ ។

សុវណ្ណៈ	ចឹងខាងកងពលពិសេសហ្នឹងមានចូលរួមជាមួយខាងណាទៀតទេ ពេលយើងឡើងទៅវាយនៅសមរភូមិម្ដងៗ?

កនៈ	ចូលរួមតើ ។

សុវណ្ណៈ	ចូលរួមជាមួយខាងណាខ្លះ?

កនៈ	ខាងហ៊ុនស៊ីនប៉ិច ។

សុវណ្ណៈ	អាហ្នឹងយើងកុំអាលនិយាយ យើងចូលមកដល់ឆ្នាំ៧៩ហើយ ចឹងឆ្នាំ៧០ កាលហ្នឹងពូគេឲ្យចូលខាងកុមារ?

កនៈ	អត់ទេ ផុតកុមារហើយ ។

សុវណ្ណៈ	ចង់និយាយថា ឆ្នាំ៧០ចូលដំបូង ឆ្នាំ៧០គេចាប់ពូឲ្យចូលទ័ព?

កនៈ	ចូលកុមារ ។

សុវណ្ណៈ	តែខាងរត់បាយឲ្យទ័ព?

កនៈ	ហ្នឹងហើយ ។

សុវណ្ណៈ	ដល់ពេលធ្វើបាន៥ខែគេឲ្យយើងចូលទ័ព?

កនៈ	បាទ ។

សុវណ្ណៈ	ដោយសារថាយើងខស្សប្រាហ៍រត់ទៅលេងឪពុកម្ដាយពេក ត្រូវទេ?

កនៈ	ហ្នឹងហើយ ។

សុវណ្ណៈ	ដល់ពេលចូលទ័ពនៅក្នុងហ្នឹង គឺគេរុញយើងឲ្យចូលទ័ពពិសេស?

កនៈ	បាទ ។

សុវណ្ណៈ ចូលទ័ពពិសេសយើងមានតួនាទីខាងគប់គ្រាប់បែក ពេលឡើងវាយម្ដងៗ ដល់ក្រោយមកពូបានចូលរួមវាយជាមួយគេនៅឆ្នាំ៧៥នេះ មកវាយបែកភ្នំពេញពូមានមកវាយជាមួយគេទេ កាលហ្នឹង?

កនៈ អត់ទេ ។

សុវណ្ណៈ អត់មកវាយទេ?

កនៈ ដកហើយ ដកទៅកងចល័ត ។

សុវណ្ណៈ ចឹងខ្ញុំចង់និយាយពីឆ្នាំពី៧០មក៧៥ហ្នឹង យើងទៅវាយនៅមុំណាខ្លះ?

កនៈ វាយតាមបន្ទាយលង្វែកមកបន្ទាយដើមគហ្នឹង កាលហ្នឹង តែជាមួយវៀតណាមខ្ញុំមិនបានទៅវាយទេ គេដកពេលហ្នឹងហើយបានគេឲ្យខ្ញុំទៅកងចល័តនោះ ។

សុវណ្ណៈ ចឹងខ្ញុំយល់ហើយចឹង ឆ្នាំ៧៥បានគេដកពូចេញពីទ័ពឲ្យទៅកងចល័តវិញ?

កនៈ បាទ ។

សុវណ្ណៈ ចឹងមកធ្វើកងចល័តមកធ្វើបានប៉ុន្មានទៀតពូ?

កនៈ ចូលបានប៉ុន្មានខែទេ បានវៀតណាមរំដោះហ្នឹង ។

សុវណ្ណៈ ពូនៅកងចល័តរហូតឬគេមានរុញពូចូលទ័ពម្ដងទៀតទេ?

កនៈ អត់ទេ ចេញពីកងចល័តខ្ញុំផ្ដាច់ខ្លួនបណ្ដោយ ។

សុវណ្ណៈ ចឹងការងាររបស់កងចល័តហ្នឹងវាលំបាកឬមិនលំបាកទេ?

កនៈ វាពិបាកមហាសែនលំបាកហើយ គេធ្វើបាបផងអីផង ដោយសារចឹងខ្ញុំឈប់ពីហ្នឹងដល់ពេលវៀតណាមចូលមករំដោះហ្នឹង ខ្ញុំចូលខាងវៀតណាមវិញ ។

សុវណ្ណៈ ចឹងពេលឆ្នាំ៧៩វៀតណាមចូលមករំដោះពូចូលខាងវៀតណាម?

កនៈ បាទ ។

សុវណ្ណៈ ចូលខាងវៀតណាម ក្រោយមកយើងធ្វើយ៉ាងម៉េចទៀត?

កនៈ វៀតណាមខ្ញុំចូលហើយ ដល់ពេលពួកខ្មែរក្រហមចូលមកវាយមក គេចាប់ខ្ញុំមកវិញទៀត ។

សុវណ្ណៈ ចឹងនិយាយចឹង ពូរៀបការឆ្នាំណា ការជាមួយមីង ឡុង នួន នេះ?

កនៈ ការនៅលើភ្នំនៅថៃ ។

សុវណ្ណៈ កាលហ្នឹងឆ្នាំណាឆ្នាំ៨០ប៉ុន្មាន៩០ប៉ុន្មាន?

កនៈ មើលការឆ្នាំ៨៣ ។

សុវណ្ណៈ ចឹងពូការហ្នឹង ពូជាអ្នកស្នើខ្លួនឯងឬមួយគេរៀបចំឲ្យ?

កនៈ គេរៀបចំឲ្យ ចាស់ៗគេរៀបចំ ។

សុវណ្ណៈ ចឹងគេរៀបចំឲ្យទេ ពូអត់មានស្នើតាមកងទេ?

កនៈ អត់ទេ ។

សុវណ្ណៈ ពូស្គាល់មីងទេ កាលហ្នឹង?

កនៈ ស្គាល់ ចាស់ៗគេស្គាល់ដល់ពេលនេះចាស់ៗឲ្យខ្ញុំយកទៅ ។

សុវណ្ណៈ ចឹងពេលវៀតណាមរំដោះបានពូនៅជាប្រជាជនធម្មតាសិន កាលហ្នឹងត្រូវទេ?

កនៈ បាទ ។

សុវណ្ណៈ ពេលនៅជាប្រជាជនធម្មតា កាលហ្នឹងយើងមកនៅខាងណាកាលហ្នឹង?

កនៈ ខ្ញុំនៅកំពង់ធំ ។

សុវណ្ណៈ ចឹងពូមករស់នៅកំពង់ធំ?

កនៈ បាទ ។

សុវណ្ណៈ ពូចេញពីរតនគិរីមករស់នៅខេត្តកំពង់ធំ?

កនៈ បាទ ។

សុវណ្ណៈ ចឹងកាលហ្នឹងមូលហេតុអីបានជាចេញពីខេត្តរតនគិរីមករស់នៅខេត្តកំពង់ធំ?

កនៈ ចុះដូចខ្ញុំថា រត់តាមកងទ័ពវៀតណាម ។

សុវណ្ណៈ រត់តាមទ័ពវៀតណាម កាលហ្នឹងមិនមែនទេ អាចពូរត់តាមទ័ពខ្មែរក្រហមទេ?

កនៈ អត់មានខ្មែរក្រហមទេ ខ្ញុំប្រាប់ប្អូនឯងមុនដំបូង ផ្ដើកងចល័តដល់ពេលវៀតណាមគេចូលមករំដោះហ្នឹងខ្ញុំក៏តាមវៀតណាមទៅ ។

សុវណ្ណៈ ចឹងកាលហ្នឹងយ៉ាងម៉េចបានជាចូលទ័ពវៀតណាម ម៉េចបានជាមកតាមទ័ពវៀតណាមចឹង?

កនៈ ចុះកាលហ្នឹងរត់បែកគ្នា កាលហ្នឹងរត់បែកគ្នាមិនដឹងណាបងដឹងណាប្អូន ដឹងណាមេក្រុមដឹងពីណាទ័ពពីណាទាហាន វារញៀររញ៉ៃគ្នានោះ ដល់ចឹងគេវាយពីដើងមកវាមិនបែកខាងក្នុងក៏ចូលខាងនោះក៏ចូលរញៀររញ៉ៃមិនដឹងថាពីមេដឹងពីណាកូន បែកគ្នារៀងៗខ្លួនទៅដល់ខ្ញុំមិនចូលតាមភូមិវិញ ដល់ចូលតាមភូមិខ្ញុំអាងប្រជាពលរដ្ឋ ហើយខ្ញុំមានម៉ែធម៌ខ្ញុំនៅកំពង់ធំខ្ញុំនៅជាមួយម៉ែធម៌ទៅ នៅជាមួយគាត់មួយឆ្នាំដល់ពេលខ្មែរក្រហមមកពីភ្នំនេះ គេមកទាក់ទងម៉ែហ្នឹង ឃើញខ្ញុំចាប់ខ្ញុំយកទៅវិញទៅ វាពីរបីត្រឡប់ចឹង ។

សុវណ្ណៈ ចឹងខ្ញុំយល់ហើយថា មុនដំបូងពូរស់នៅក្នុងភូមិសិន ដល់ពេលរស់នៅក្នុងភូមិអត់មានបងប្អូនអត់មានញាតិមិត្តក៏មករស់នៅជាមួយម្ដាយធម៌នៅកំពង់ធំនេះ ចេញពីរតនគិរីមកនៅកំពង់នេះ នៅបានមួយឆ្នាំខាងទ័ពខ្មែរក្រហមគេចេញចូលនៅក្នុងខេត្តកំពង់ធំ គេឃើញពូ ចឹងគេចាប់ពូឲ្យចូលទ័ពខាងខ្មែរក្រហមវិញ?

កនះ បាទ ។

សុវណ្ណៈ ចឹងកាលហ្នឹងប្រហែលជាឆ្នាំ៧០ គេឲ្យចូលវិញ រស់នៅបានមួយឆ្នាំត្រូវទេ?

កនះ មើល៨៣-៨៤ឆ្នាំ៨៥ខ្ញុំចេញមកព្រៃ ។

សុវណ្ណៈ ចឹង៨៥ចេញមកព្រៃ?

កនះ បាទ ។

សុវណ្ណៈ ចឹងមានន័យថា ឆ្នាំ៨៥ខាងខ្មែរក្រហមគេចាប់ពូ?

កនះ បាទ ។

សុវណ្ណៈ ចឹងនៅកំពង់ធំបានច្រើនឆ្នាំដែរ?

កនះ បានបីឆ្នាំ ។

សុវណ្ណៈ ចឹងបើបីឆ្នាំពូមិនមែនការឆ្នាំ៨៣ទេ?

កនះ ៨៣ខ្ញុំឡើងមកដល់ការភ្ជាម ។

សុវណ្ណៈ ក្រែងទ័ពខ្មែរក្រហមចាប់ពូចូលព្រៃឆ្នាំ៨៥តើ?

កនះ អើ ។

សុវណ្ណៈ ចឹងបើ៨៥ ម៉េចបានពូថា ការនៅលើភ្នំឆ្នាំ៨៣កើត?

កនះ មើលប្រទ្បំបាត់ហើយ វង្វេងបាត់ហើយ ។

សុវណ្ណៈ ចឹងមើលទ័ពខាងវៀតណាមរំដោះបានឆ្នាំ៧៩ ចឹង៧៩ពូមកនៅកំពង់ធំ ចេញពីរតនគិរីមក នៅកំពង់ធំនេះ មកនៅជាមួយម្ដាយធម៌ មកនៅជាមួយម្ដាយធម៌យើងបានធ្វើអីខ្លះពូ?

កនះ ធ្វើស្រែ ។

សុវណ្ណៈ ចឹងក្រៅពីធ្វើស្រែមានធ្វើអីទៀត?

កនះ ទៅរកវល្លិ៍បោចលក់ វល្លិ៍នៅព្រៃឡង់ ។

សុវណ្ណៈ ចឹងភូមិមកនៅកំពង់ធំ មកនៅស្រុកណាកាលហ្នឹង?

កនះ ស្រុកស្ទោង ។

សុវណ្ណៈ តែពូចូលព្រៃបោចវល្លិ៍អីនៅខាងព្រៃឡង់នេះ?

កនះ បាទ ។

សុវណ្ណៈ ចឹងពូជួបទ័ពខ្មែរក្រហមនៅក្នុងព្រៃទេ?

កនះ ជួបនៅក្នុងភូមិ ។

សុវណ្ណៈ ចឹងខ្មែរក្រហមចូលមកក្នុងភូមិ?

កនះ ចូលភូមិមករកអង្ករអីហូបនោះ ។

សុវណ្ណៈ ចឹងនៅកំពង់ធំនៅបានយូរទេ កាលហ្នឹង?

កនៈ នៅបានប្រហែលជាពីរឆ្នាំ ។

សុវណ្ណៈ ចឹងនៅប្រហែលជាពីរឆ្នាំក្រោយមកក៏ទ័ពខ្មែរក្រហមឃើញពូ គេថាយ៉ាងម៉េចពេលគេឃើញពូ?

កនៈ គេសួរម៉ែថា កូនម៉ែឯងកូនពិតប្រាកដឬកូនចិញ្ចឹម ម៉ែថា កូនចិញ្ចឹមកូនពីណាមក កូនបែកពីឆ្នាំ៧៩ មិនដឹងមកពីណាមកទេ ខ្ញុំមិនស្គាល់ភូមិស្រុកអីទេ បេះយកមកចិញ្ចឹមមកវាអត់បាយ ដល់ចឹងខាងខ្មែរក្រហមថា ខ្ញុំសុំយកទៅវិញ ។

សុវណ្ណៈ ចឹងម្ដាយធម៌ពូថា យ៉ាងម៉េច?

កនៈ មានថា ម៉េច ។

សុវណ្ណៈ ចឹងនៅបានប្រហែលជាពីរឆ្នាំឃើញពូ ចាប់ចូលវិញទៅ?

កនៈ បាទ ។

សុវណ្ណៈ កាលហ្នឹងពូព្រមទេ?

កនៈ ព្រមខ្លះយំខ្លះ រត់ទៅផ្ទះខ្លះ ។

សុវណ្ណៈ ចឹងគេបង្ខំទេ?

កនៈ បាទ ។

សុវណ្ណៈ យើងអត់មានចិត្តចង់ចូលទេ?

កនៈ អត់ទេ ឃើញថា លំបាកហើយ ចេញពីលំបាកមកលំបាកទៀតខ្ញុំមិនចង់បាន ។

សុវណ្ណៈ ចឹងកាលហ្នឹងគេនាំពូមកខាងភ្នំដងរែកនេះគេនាំពូមកតាមផ្លូវណាកាលហ្នឹង?

កនៈ នេះតាមមួយផ្លូវភ្នំដងរែកនេះ ។

សុវណ្ណៈ តែយើងដើរក្នុងព្រៃឬដើរតាមណា?

កនៈ ដើរតាមក្នុងព្រៃ ខាងខ្មែរក្រហមមានផ្លូវណាដើរ មានតែដើរកាត់ព្រៃ ។

សុវណ្ណៈ កាត់កន្លែងណាខ្លះកាលហ្នឹង មុនមកដល់អន្លង់វែងយើងកាត់តាមព្រៃមកដល់កន្លែងណាខ្លះ?

កនៈ ចេញពីកំពង់ធំ មកសំបកអរ ចេញពីសំបកអរ មកសៀមរាម ចេញពីសៀមរាបមកទៀតទៅ ។

សុវណ្ណៈ ចឹងយើងធ្វើដំណើរតាមផ្លូវទំរាំមកដល់ភ្នំអស់រយៈពេលប៉ុន្មានទៅ?

កនៈ អស់រយៈពេលមួយខែ ។

សុវណ្ណៈ ចឹងរយៈពេលមួយខែយើងបានអីហូប បានអីផឹក?

កនៈ	អង្គរគេយកពីក្នុងមក អង្គរទិញពីប្រជាពលរដ្ឋមក កាលនោះខ្ញុំមិនសូវដឹងទេ គេរញ៉េរញ៉ៃពេក ខ្ញុំមិនយល់ពីវិន័យរបស់គេផង ចេះតែទៅតាមគេទៅ ។

សុវណ្ណៈ	ចឹងពូទៅតាមគេ គេមានពន្យល់ប្រាប់ថា យ៉ាងម៉េចខ្លះកាលហ្នឹង មានពន្យល់ប្រាប់អីខ្លះទេពេលហ្នឹង?

កនៈ	គេថា យើងត្រូវចេញមកតស៊ូបើមិនចឹងយួនវាយកទឹកដីអស់ ដល់ពេលទៅដល់ភ្នំខ្ញុំបកមកវិញដដែល ខ្ញុំមកផ្ទះវិញដដែល ។

សុវណ្ណៈ	ចឹងយើងទៅដល់ភ្នំ យើងទៅដល់ភ្នំកន្លែង១០០០ប៉ុន្មានកាលហ្នឹង?

កនៈ	១០០២ ។

សុវណ្ណៈ	ចឹងទៅដល់១០០២?

កនៈ	បាទ!ដល់ហើយត្រឡប់មកផ្ទះវិញ ។

សុវណ្ណៈ	ទៅដល់១០០២ហ្នឹងបានរយៈពេលប៉ុន្មានបានយើងរត់មកផ្ទះវិញ?

កនៈ	ទៅហ្នឹងវាលំបាកពេក មិនដឹងណាផ្ទះមិនដឹងណាសំបែង ខ្ញុំខ្ជិលរញ៉េរញ៉ៃជាមួយថៃផង ថៃវាដេញផងអីផង បានបន្តិចខ្ញុំរត់មកផ្ទះវិញទៅ ។

សុវណ្ណៈ	ចឹងខ្ញុំចង់ដឹងថា ពូនៅនោះបានរយៈពេលប៉ុន្មានខែប៉ុន្មានឆ្នាំបានយើងរត់មកផ្ទះវិញ?

កនៈ	មួយអាទិត្យ ។

សុវណ្ណៈ	ម៉េចបានជាលឿនម៉េះ គេឲ្យយើងមកវិញបាន ម៉េចបានយើងមកវិញបាន?

កនៈ	លួចរត់មកវិញ ។

សុវណ្ណៈ	ចឹងលួចមកវិញ គេមានទៅតាមចាប់យើងមកវិញទេ?

កនៈ	តាមចាប់ណាទៀត បើយើងគេចនៅកន្លែងណាផ្សេងកុំឲ្យគេមកដល់ ។

សុវណ្ណៈ	ចឹងពូរត់មកវិញ ពូស្គាល់ផ្លូវមកវិញដែរ?

កនៈ	ស្គាល់ ។

សុវណ្ណៈ	ម៉េចបានពូស្គាល់?

កនៈ	ស្គាល់តាមពួកអ្នកទៅធ្វើ«ក៥»នោះ ។

សុវណ្ណៈ	ចឹងពេលរត់មកវិញ ពូជួបអ្នកធ្វើ«ក៥»តាមផ្លូវហ្នឹង?

កនៈ	បាទ ។

សុវណ្ណៈ	ចឹងជួបអ្នកធ្វើ«ក៥»ពូថាយ៉ាងម៉េច?

កនៈ	ថា ខ្ញុំរត់ចេញពីខ្មែរក្រហម ថាខ្ញុំមិនចេះនៅមិនដឹងថាណាកោះណាគ្រោយទេ ថៃក៏ដេញគេខឹងកាប់ឈើគេ ។

សុវណ្ណៈ កាប់ឈើអីគេកាលហ្នឹង?

កនៈ ឈើគេដាំរាល់ថ្ងៃហ្នឹង គេដាំក្រញូងរាល់ថ្ងៃ ទៅលួចឈើគេមួយថ្ងៃៗមិនមែនតិចទេ យើងទៅកាប់ឈើគេដាំហ្នឹង គេមិនទីង គេដាំដើមក្រញូង ដើមបេង ដើមកកោះ ខាងក្រសួងបរិស្ថានគេ ថៃមានដាំអីទេ ដាំតែអាហ្នឹងឯង ។

សុវណ្ណៈ ចឹងកាលយើងនៅតស៊ូលើភ្នំយើងលួចកាប់ឈើអីគេដែរ?

កនៈ ហ្នឹងហើយ ។

សុវណ្ណៈ ចឹងកាប់ឈើលក់ឲ្យខាងណា?

កនៈ អត់លក់ទេ កាប់ឈើធ្វើគល់អង្រឹងយើងហ្នឹងណាស់ យើងចងអង្រឹងចឹងយើងធ្វើបង្គោល ។

សុវណ្ណៈ ចឹងយកធ្វើបង្គោលអង្រឹង?

កនៈ បាទ!ដល់ចឹងយើងមិនកាប់ឈើគេ ឈើហ្នឹងគេមិនដាំ មិនមែនកាប់ម្នាក់ឯងណា កាប់គ្នាច្រើនមិនវាលរបស់គេ ១០នាក់៣០នាក់១០០នាក់នោះ គេមិនចាប់ ។

សុវណ្ណៈ ចឹងពេលពូរត់មកតាមផ្លូវជួបខាង“ក៥”ហ្នឹងគេមានសួរនាំយើងខ្លះទេ?

កនៈ សួរតើ ។

សុវណ្ណៈ គេសួរថា យ៉ាងម៉េច?

កនៈ ប្អូនមកពីណា ខ្ញុំមកពីខ្មែរក្រហមខ្ញុំខ្ជិលនៅរញ៉េរញ៉ៃពេក ជួប“ក៥”អត់ស្គាល់គានោះផងពេលគាត់ទៅផ្ទះទៅតាមគាត់ទៅឡើងឡាន ។

សុវណ្ណៈ ចឹងកាលពូត្រឡប់ទៅវិញ ត្រឡប់ទៅខាងណា?

កនៈ ទៅកំពង់ធំវិញ ។

សុវណ្ណៈ ចឹងក្រោយមកមានគេចាប់ម្តងទៀតទេ? .

កនៈ អត់មានចាប់ទេ ឈប់ហើយ ។

សុវណ្ណៈ ចឹងម៉េចពូបានមកនៅនេះកើត?

កនៈ ចុះកាលនោះគេមិនផ្តាច់ខ្លួនធ្វើសមាហរណ៍កម្ម មកដើររកដីរកស៊ី មករកដី នៅក្នុងមានដីតិចៗដល់ឃើញគេមកចឹងមិនមក មករកដីហ្នឹងគេ ។

សុវណ្ណៈ ចឹងពូមករស់នៅហ្នឹងម្តងទៀតបន្ទាប់ពីមានសមាហរណ៍កម្មហើយទេ?

កនៈ បាទ ។

សុវណ្ណៈ ចឹងដោយសានៅនោះមិនសូវមានដីធ្លី អត់មានជីវភាពរកបាននិងគេក៏សម្រេចចិត្តមកនៅនេះទៅ មកនៅតាមគេឯងទៅ?

កនៈ ហ្នឹងហើយ ។

សុវណ្ណៈ ហើយកាលហ្នឹងពូពូថាយ៉ាងម៉េច កាលហ្នឹង ពូថា ខាងហ្នឹងយ៉ាងម៉េចបានយើងមកនៅខាងនេះ?

កនៈ គេថា សម្បូរដី ដីអត់ទិញ អត់លក់ ចាប់ខ្លួនឯងប៉ុន្មានទៅប៉ុណ្ណឹង មកតាមគេតាមឯង ។

សុវណ្ណៈ កាលពូមកលើភ្នំ១០០២ហ្នឹង ពូចូលជាមួយកងពលណាពូមានដឹងទេ?

កនៈ អត់ដឹងទេ ។

សុវណ្ណៈ ចឹងម៉េចបានជាពូថា បានចូលជាមួយកងពល៨០១ កងពលរបស់តាសានអីនោះតា០៥អីនោះ?

កនៈ តាំងពីឆ្នាំ៧០ទេ ហ្នឹងនោះ ។

សុវណ្ណៈ ចឹងកាលពូមកនៅដំបូងពូមកនៅខាងណាកាលហ្នឹង ពេលគេសមាហរណ៍កម្មហើយពូមកនៅខាងណា?

កនៈ មកនៅខាងអន្លង់វែង ។

សុវណ្ណៈ មកនៅអន្លង់វែងមកនៅម្តុំណា?

កនៈ មួយដួរត្រពាំងប្រិយ៍ហ្នឹង ។

សុវណ្ណៈ ចឹងក្រោយមកមកនៅណាទៀត ចេញពីត្រពាំងប្រិយ៍?

កនៈ មកនៅត្រពាំងប្រាសាទ ខាងទំនប់ដាច់ ។

សុវណ្ណៈ មកនៅខាងណាទៀត ចេញពីទំនប់ដាច់?

កនៈ មកនេះនៅហ្នឹងបណ្តោយ ។

សុវណ្ណៈ ចឹងកាលហ្នឹងមកមុនសមាហរណ៍កម្មឬក្រោយសមាហរណ៍កម្ម?

កនៈ មុន ។

សុវណ្ណៈ ចឹងមុនសមាហរណ៍កម្មពូមកនៅខាងអន្លង់វែងនេះទេ?

កនៈ បាទ ។

សុវណ្ណៈ ពូចុះពីភ្នំមកនៅអន្លង់វែង?

កនៈ មិនពូខ្ញុំថាទៅស្រុកទេ ។

សុវណ្ណៈ ចឹងពូមកនៅអន្លង់វែងកើតដែលបើគេមិនទាន់ធ្វើសមាហរណ៍កម្មផងហ្នឹង នៅតំបន់បាញ់គ្នានៅឡើយ?

កនៈ បាញ់កាលហ្នឹងមិនមានអ៊ុនគាក់ មានអ៊ុនគាក់មានពីណាបាញ់ ដល់ផុតពីអ៊ុនគាក់ហើយបានគេបាញ់គ្នាមួយឈុតទៀត ។

សុវណ្ណៈ ចឹងមានន័យថា ឆ្នាំ៩២-៩៣ពូត្រឡប់មកនៅនេះវិញ មកនៅអន្លង់វែងនេះ?

កនៈ	បាទ ។

សុវណ្ណៈ	ចឹងដោយសារមានដីធ្លី?

កនៈ	បាទ ។

សុវណ្ណៈ	ចឹងពេលពូមកនៅចូលជាមួយខ្មែរក្រហមហើយកាលហ្នឹង?

កនៈ	អត់ចូលទេ មានចូលណាទៀត ។

សុវណ្ណៈ	ព្រោះថា ឆ្នាំ៩២-៩៣ខ្មែរក្រហមគេនៅដែរ?

កនៈ	ខ្មែរក្រហមនៅលើភ្នំ នៅនេះខ្មែរ ។

សុវណ្ណៈ	ចឹងនៅក្រោមនេះប្រជាជនធម្មតា កាលជំនាន់អ៊ុនតាក់ហ្នឹង ដល់ពេលទាហាននៅលើភ្នំទេ?

កនៈ	បាទ!អន្លង់វែងប្រជាជនកំណើតគេនៅហ្នឹង គេមកពីសៀមរាបហ្នឹង គេនៅហ្នឹងគេមានទៅណា ។

សុវណ្ណៈ	ពូចូលមកនៅមុនអ៊ុនតាក់ឬពេលអ៊ុនតាក់?

កនៈ	មុនអ៊ុនតាក់ ។

សុវណ្ណៈ	មុនអ៊ុនតាក់ប្រហែលជាប៉ុន្មានខែប៉ុន្មានឆ្នាំ?

កនៈ	មុនអ៊ុនតាក់ប្រហែលជាពីរខែ ។

សុវណ្ណៈ	ចឹងម៉េចបានដឹងថា នៅនេះមានអ៊ុនតាក់ ម៉េចបានពូដឹងថា មានអ៊ុនតាក់នៅអន្លង់វែងយើងឮតាមគេឬយ៉ាងម៉េច?

កនៈ	ឮតាមគេ ។

សុវណ្ណៈ	ឮតាមគេអ្នកក្នុងភូមិនិយាយ?

កនៈ	ហ្នឹងហើយ ។

សុវណ្ណៈ	ចឹងកាលហ្នឹងមានគេមកនៅនេះច្រើនទេ?

កនៈ	មានច្រើនដែលមានមកប៉ុន្មានភូមិ ។

សុវណ្ណៈ	ចឹងពេលយើងមកម្តងទៀតយើងធ្វើដំណើរតាមណាម្តងហ្នឹង?

កនៈ	កាលហ្នឹងមកចាប់ដីទុក ។

សុវណ្ណៈ	តែយើងដើរមកឬជិះអីមក?

កនៈ	ដើរ អត់មានផ្លូវអត់មានឡានជិះទេ ។

សុវណ្ណៈ	ដើរព្រៃអីទៅ?

កនៈ	ជិះរទេះ ។

សុវណ្ណៈ	ហើយកាលហ្នឹង ពូរៀបការហើយនៅ?

កនៈ ការហើយ ។

សុវណ្ណៈ ចឹងពូថា ការលើភ្នំទេ?

កនៈ ការលើភ្នំហ្នឹងហើយបាននាំប្រពន្ធមកនេះ មកស្រុកហ្នឹង ចុះមកដីខ្មែរវិញហ្នឹង ។

សុវណ្ណៈ ចឹងការលើភ្នំហើយបានចុះមកក្រោមវិញ?

កនៈ ចុះមកជួបពួក"ក៥"ហ្នឹង ។

សុវណ្ណៈ ចឹងពូទៅនៅហ្នឹងយូរដែលមិនមែននៅមួយអាទិត្យទេ ព្រោះយើងបានការអី?

កនៈ សម័យហ្នឹងបើមិនការម៉េចបានទ័ពប្រើ ទាល់ការបានយកប្រពន្ធទុកនោះបានប្តីចុះមកមុខ នយោបាយគេធ្វើចឹង បើមិនធ្វើចឹងម៉េចបានមនុស្សមកវាយ ។

សុវណ្ណៈ ចឹងពេលពូទៅដល់លើភ្នំពូការទៅ?

កនៈ ហ្នឹងហើយ ។

សុវណ្ណៈ ចឹងពូការហើយប្រពន្ធពូនៅលើភ្នំ?

កនៈ គេឲ្យប្រពន្ធនៅលើភ្នំ ។

សុវណ្ណៈ ចឹងប្តីមកវាយនៅខាងក្រោមនេះ?

កនៈ ហ្នឹងហើយ យើងមិនដាច់ខាតនឹកឃើញអាណិតប្រពន្ធចឹងយើងនាំប្រពន្ធមកផ្ទះមក ។

សុវណ្ណៈ ដល់ពេលយើងវាយមិនអាចទាំទ្របានយើងនាំប្រពន្ធរត់ទៅកំពង់ធំវិញទៅ?

កនៈ ហ្នឹងហើយ នឹកឃើញថាយកទុកណា ។

សុវណ្ណៈ ចឹងយើងវាយជាមួយខាងណាកាលហ្នឹង?

កនៈ វាយជាមួយពួកតាពឹម ហ្នឹងកងពលនេះហ្នឹង ។

សុវណ្ណៈ តាពឹម កងពលប៉ុន្មាន?

កនៈ កងពល៩៨០ វាយចំរុះគ្នាកាលហ្នឹង គ្រប់កងពល ។

សុវណ្ណៈ ចឹងពូមានដឹងថា កងពល៩៨០ហ្នឹងគេមានបែកចែកប៉ុន្មានវរសេនាធំដែលពូ?

កនៈ មិនដឹងជាប៉ុន្មានគេ ខ្ញុំមិនស្គាល់ដែរ ។

សុវណ្ណៈ ប៉ុន្តែនៅក្នុងកងពល៩៨០ហ្នឹង ពូនៅក្នុងក្រុមណាដែរ?

កនៈ ខ្ញុំ៧០៤វរសេនាធំ១៨ ។

សុវណ្ណៈ កាលហ្នឹងគេឲ្យពូកាន់ខាងអីគេ?

កនៈ ខ្ញុំមានកាន់ខាងអីទេ ខ្ញុំធ្វើប្រជាពលរដ្ឋធម្មតា អត់មានធ្វើអីទេ ។

សុវណ្ណៈ ដល់ពេលយើងវាយយើងច្រើនវាយជាមួយខាងណា ពេលចុះពីភ្នំមកវាយនៅក្រោម?

កនៈ ខ្ញុំអត់មានបានរ៉ាយទេ គេរ៉ាយតែគេទៅខ្ញុំចុះពីភ្នំហើយខ្ញុំទៅផ្ទះ ខ្ញុំមានទៅរ៉ាយជាមួយគេណាទៀត ។

សុវណ្ណៈ ក្រែងលោរ៉ាយជាមួយគេសិន?

កនៈ អត់ទេ ។

សុវណ្ណៈ ចឹងប្រពន្ធពូនៅលើភ្នំ ពូថាចុះមកក្រោមមករ៉ាយតើ?

កនៈ យើងមកទាំងប្រពន្ធអីមកហ្នឹង ចុះមកជួបពួក"ក៥"ហ្នឹងណាស់ មិនទៅរ៉ាយជាមួយគេណាទៀត ។

សុវណ្ណៈ ចឹងគ្នាពូដែលនៅទ័ពជាមួយគ្នានោះគេមិនដឹងថាពូ លួចរត់ទេ?

កនៈ រត់ កាលហ្នឹងទោះតាមម្នាក់ឯង ម៉េចតាមកើត បើយើងទៅតែម្នាក់ឯងមិនដឹងជាប្រកណាកាលហ្នឹង ។

សុវណ្ណៈ ចឹងគេឲ្យប្រពន្ធពូមកដែលកាលហ្នឹង ហើយប្រពន្ធពូនៅលើភ្នំម៉េចទ័ពខាងក្រោមគេនៅរ៉ាយហ្នឹងម៉េចគេឲ្យពូមកកើត ។

កនៈ ខ្ញុំនាំប្តីប្រពន្ធខ្ញុំចុះហ្នឹង ខ្ញុំចុះតាមថៃតើ ថៃនាំមកតើ ថៃគេបញ្ជូនឲ្យពួក"ក៥"ទៅតាមហ្នឹងមក មកតាមគេមក ។

សុវណ្ណៈ តែយើងបានរ៉ាយជាមួយគេសិនទេ?

កនៈ អត់ទេ ខ្ញុំមកបណ្តោយទៅ ។

សុវណ្ណៈ កាលហ្នឹង ពូមានកូនហើយនៅ?

កនៈ គ្មានទេ ។

សុវណ្ណៈ កាលយើងការបានប៉ុន្មានខែ?

កនៈ ដឹងការបានប៉ុន្មានខែទេ កាលហ្នឹង និយាយការភ្លាមចុះភ្លាមគេមិនឲ្យនៅជាមួយប្រពន្ធទេ ។

សុវណ្ណៈ មឹងការហ្នឹង មឹងការជាមួយពូឆ្នាំណាកាលហ្នឹង?

កនៈ ប្រពន្ធ និយាយថា ខ្ញុំមិនចាំទេ ច្បាស់ទេ ។

សុវណ្ណៈ ចឹងការលើភ្នំមឹង?

កនៈ ចាស!ការលើភ្នំហ្នឹង ។

សុវណ្ណៈ ចឹងយើងមិនដឹងថា ឆ្នាំប៉ុន្មាន៨០ប៉ុន្មានអីទេ?

កនៈ អត់ដឹងទេ ។

សុវណ្ណៈ តែការហ្នឹងនៅបានយូរទេមឹង ទំរាំយើងរត់ទៅកំពង់ធំវិញ យើងនៅបានរយៈពេលដែរ?

កនៈ ដូចខ្ញុំប្រាប់ប្អូនមិញហ្នឹង ការហើយខ្ញុំចុះមកភ្លាម«ប្រពន្ធនិយាយថា ការហើយបីទៅប្អូនឆ្នាំបានគេឲ្យជួបគ្នាម្តង» ។

សុវណ្ណៈ ចឹងបីប្អូនឆ្នាំជួបគ្នាម្តងកាលហ្នឹង?

កនៈ ចាស ។

សុវណ្ណៈ ចឹងពូនៅប្រចាំខាងក្រោម?

កនៈ នៅខាងក្រោម ។

សុវណ្ណៈ ហើយមីងនៅលើបីប្អូនឆ្នាំបានជួបគ្នាម្តង?

កនៈ ចាស ។

សុវណ្ណៈ ចឹងកាលហ្នឹងម៉េចរត់ទៅកំពង់ធំកើត?

កនៈ អត់មាននៅកំពង់ធំទេ នៅដីថៃ ។

សុវណ្ណៈ ចឹងមីងនៅជំរំ ដល់ពេលពូប្រចាំការនៅក្រោមទេ?

កនៈ ចាស ។

សុវណ្ណៈ ចឹងពេលពូរត់មកវិញ ពូមានជួបជាមួយខាងទ័ពវៀតណាម ជួបទ័ពរដ្ឋាភិបាលទេពូ?

កនៈ ជួប ។

សុវណ្ណៈ ជួបយើងធ្វើម៉េច កាលហ្នឹង?

កនៈ ជួបសុំគេទៅថាយើងមិនចេះនៅ ។

សុវណ្ណៈ ចឹងគេឲ្យយើងឆ្លងកាត់ដែលកាលហ្នឹង?

កនៈ ឆ្លងកាត់ ។

សុវណ្ណៈ ចឹងគេមានថាអីខ្លះឲ្យយើងទេ?

កនៈ អត់ថាទេ យើងថា ឲ្យតែយើងថាផ្តាច់ខ្លួនពីខ្មែរក្រហមគេមិនថាអីទេ កុំឲ្យយើងវាយគេអាហ្នឹងគេធ្វើយើងហើយ យើងធ្វើប្រជាពលរដ្ឋតើ មិនធ្វើទាហានអីណា ។

សុវណ្ណៈ ចឹងពេលពូត្រឡប់នៅកំពង់ធំហើយដល់ឆ្នាំ៩២-៩៣មានអ៊ុនតាក់អីក៏ពូត្រឡប់មកវិញមក?

កនៈ បាទ ។

សុវណ្ណៈ ចឹងមកនៅវិញយើងធ្វើប្រជាជនធម្មតាទេ?

កនៈ ធ្វើធម្មតា ។

សុវណ្ណៈ អត់មានចូលទ័ពទេ?

កនៈ អត់ទេ ។

សុវណ្ណៈ ចឹងការហូបចុកមានរបបបើកឲ្យយើងទេ?

កនៈ	រកហូបខ្លួនឯង ។

សុវណ្ណៈ	អត់មានបើកឲ្យទេ?

កនៈ	បើអីណាបើយើងធ្វើប្រជាពលរដ្ឋ មិនរកខ្លួនឯង ។

សុវណ្ណៈ	ចឹងទ័ពបានគេបើកឲ្យ?

កនៈ	បាទ ។

សុវណ្ណៈ	ដល់ពេលហ្នឹងយើងរកស៊ីយ៉ាងម៉េចពេលហ្នឹង?

កនៈ	រកស៊ីធ្វើស្រែចម្ការទៅ តាមគេលក់នេះលក់នោះទៅ ។

សុវណ្ណៈ	ចឹងយើងមានលក់អីឲ្យគេដែរ?

កនៈ	លក់ ។

សុវណ្ណៈ	ចឹងលក់យើងប្រើលុយអីគេលក់?

កនៈ	លុយរដ្ឋាភិបាលនេះ ។

សុវណ្ណៈ	មិនមែនលុយបាតទេ?

កនៈ	អត់ទេ ។

សុវណ្ណៈ	ចឹងនិយាយថា ពូមកនៅអន្លង់វែង នៅអន្លង់វែងកាលហ្នឹងមានអ៊ុនតាក់នោះមានលុយរដ្ឋាភិបាលមកពីណា?

កនៈ	មានតើ កាលឆ្នាំប៉ុន្មាននោះ ចាយតាំងពីមួយកាក់ កាលនោះ ។

សុវណ្ណៈ	កាលចរចារជាមួយគ្នាកាលហ្នឹង?

កនៈ	ហ្នឹងហើយ មានអីអត់ លុយបាតមានតែពួកខ្មែរក្រហមទេ មានលុយបាតនោះ រដ្ឋាភិបាលមានប្រើលុយបាតណា ។

សុវណ្ណៈ	ដល់ពេលប្រជាជនចាយលុយធម្មតា របស់រដ្ឋាភិបាលកាលជំនាន់អ៊ុនតាក់ហ្នឹង?

កនៈ	បាទ ។

សុវណ្ណៈ	ចឹងកាលហ្នឹងយើងច្រើនរកស៊ីអីជាមួយថៃកាលហ្នឹង?

កនៈ	ដូចជាស្រូវអង្ករលក់ឲ្យគេ លក់ចេញចូលពីប៉ោយប៉ែត ស្មាច់អីហ្នឹង ។

សុវណ្ណៈ	មានទៅស៊ីឈ្នួនអីឲ្យគេខ្លះទេ?

កនៈ	អត់ទេ ។

សុវណ្ណៈ	ពូនៅតែក្រោមទេ?

កនៈ	ហ្នឹងហើយ ។

សុវណ្ណៈ	ចឹងពូដែលជួបតាម៉ុក ទេ?

កនៈ	មិនដឹងជាតាម៉ុក មុខយ៉ាងម៉េចផង ។

សុវណ្ណៈ	ឮឈ្មោះ តែមិនដែលជួបទេ?

កនៈ	បាទ!មិនតាម៉ុក មុខយ៉ាងម៉េចផង ។

សុវណ្ណៈ	ចុះប៉ុល ពត?

កនៈ	ប៉ុល ពត ស្រេចហើយមិនដឹងមុខយ៉ាងម៉េចទេ ។

សុវណ្ណៈ	នួន ជា?

កនៈ	អត់ស្គាល់ទេ ។

សុវណ្ណៈ	សុន សេន?

កនៈ	អត់ស្គាល់ទេ ដូចខ្ញុំថា ខ្ញុំប្រជាពលរដ្ឋ ។

សុវណ្ណៈ	ខៀវ សំផន អត់ដែរ?

កនៈ	អត់ទេ ។

សុវណ្ណៈ	ចឹងមេខ្មែរក្រហមធំៗពូច្រើនជួបពីណាគេ?

កនៈ	អត់មានជួបអ្នកធំៗទេ ជួបអ្នកតូចតាចគ្នាឯង អ្នកធំនៅបាងកកនោះ គេមិនមែននៅជាមួយយើងណា ដីថៃនោះ គេនិយាយតាមគេអូ យើងមានស្គាល់គេណា ។

សុវណ្ណៈ	ចឹងទាហានខ្មែរក្រហមគេរកស៊ីអីជាមួយថៃកាលហ្នឹង?

កនៈ	អត់មានជួញដូរទេ ពួកហ្នឹងគេមានរបបបើករបស់គេ ។

សុវណ្ណៈ	ចង់និយាយថា គេរកស៊ីឈើ វត្ថុបុរាណជាមួយថៃ?

កនៈ	ខាងតាម៉ុក គេលក់ឈើមែន ខ្ញុំឮតាមគេថាទេ ។

សុវណ្ណៈ	ចឹងរកស៊ីឈើជាមួយថៃ?

កនៈ	ហ្នឹងហើយ ។

សុវណ្ណៈ	ចឹងមានរកស៊ីវត្ថុបុរាណជាមួយថៃទេ?

កនៈ	អត់ដឹងទេ ។

សុវណ្ណៈ	ឈើហ្នឹងគេរកស៊ីឈើអីគេកាលហ្នឹង?

កនៈ	ដើមឈើទាលអីហ្នឹងឯង កាត់លក់ៗ ។

សុវណ្ណៈ	ចឹងកាត់លក់ៗចេញឲ្យថៃទៅ?

កនៈ	ហ្នឹងហើយថៃដឹកអូសយកទៅ យើងមានដឹកណាថៃគេចូលមកអូសខ្លួនគេ ។

សុវណ្ណៈ	ចឹងសព្វថ្ងៃអ្នកជិតខាងយើងទាក់ទងគ្នាធម្មតាទេ?

កនៈ	ធម្មតាមានកើតអី ។

សុវណ្ណៈ ចឹងយើងទាក់ទងគ្នាច្រើននិយាយរឿងអីគេ?

កនៈ មាននិយាយរឿងអី និយាយរឿងធ្វើស្រែចម្ការហ្នឹង ។

សុវណ្ណៈ ចឹងមាននិយាយរឿងអីផ្សេងទៀតទេ?

កនៈ អត់ទេ ។

សុវណ្ណៈ ចឹងខ្ញុំចង់និយាយថា ពូខស្យាហ៍និយាយអីជាមួយអ្នកជិតខាងក្រៅពីការងាររកស៊ីធ្វើស្រែចម្ការ យើងដើរពិភាក្សាអីនិយាយគ្នាជាមួយអ្នកជិតខាងខ្លះទេ?

កនៈ មានតែប៉ុណ្ណឹងឯង និយាយធ្វើស្រែចម្ការដាំដំឡូង ដាំសណ្តែក ដាំល្ហុងណាមានអី ខែធ្វើស្រែធ្វើស្រែ ខែដាំដំឡូងដកដំឡូងអីទៅមានតែប៉ុណ្ណឹង មាននិយាយអីទេ ។

សុវណ្ណៈ ពេលយើងនិយាយចឹង យើងមានអារម្មណ៍ថាយើងសប្បាយទេ?

កនៈ បើមិនសប្បាយយ៉ាងម៉េច ការងារមួយទៀត ខ្លួនចេះតែប្រឡងប្រណាំងគ្នាទៅមានអីមានទៅអ្នកណាអត់ៗទៅ ។

សុវណ្ណៈ តែយើងនិយាយគ្នាទាំងអារម្មណ៍សប្បាយឬអារម្មណ៍មិនសប្បាយ?

កនៈ សប្បាយខ្លះទុក្ខខ្លះ ដូចជាប្រពន្ធខ្ញុំសព្វថ្ងៃឈឺតែរហូតហ្នឹង ។

សុវណ្ណៈ ចឹងកាលពូនៅក្នុងរបបខ្មែរក្រហមហ្នឹងមានដែលពិភាក្សាគ្នាទេ?

កនៈ អត់មានទេ អត់ហ៊ាននិយាយទេ ។

សុវណ្ណៈ ម៉េចអត់ហ៊ាននិយាយកាលហ្នឹង?

កនៈ គេថា យើងក្បត់ ។

សុវណ្ណៈ ថាយើងក្បត់យ៉ាងម៉េច?

កនៈ ថា យើងក្បត់ពីគេ ។

សុវណ្ណៈ ចឹងគេធ្វើយ៉ាងម៉េចដាក់យើង?

កនៈ មានអី ចឹងបានមិនហ៊ាននិយាយហ្នឹង ។

សុវណ្ណៈ នៅក្នុងរបបហ្នឹង ពូមានដែលឃើញគេយកមនុស្សទៅសម្លាប់អីទេ?

កនៈ អត់មានឃើញទេ មិនដឹងជាគេធ្វើម៉េច បានដឹងត្រឹមដាក់គុកហើយ មិនដឹងគេដឹកទៅណាទៀតខ្ញុំមិនដឹងដែរ ។

សុវណ្ណៈ ដែលឃើញគេវាយធ្វើបាបមនុស្សទេ នៅក្នុងរបបហ្នឹង?

កនៈ អត់មានទេ លោខុសពីកន្លែងខ្ញុំ ទឹកដីខ្ញុំអត់មានទេ ។

សុវណ្ណៈ តែច្រើនគេហៅទៅអប់រំ?

កនៈ ហៅទៅអប់រំ បើខុសខ្លាំងបញ្ជូនគុក គេបញ្ចេញពីគុកគេឲ្យធ្វើការធម្មតា រឿងវាយតប់ខ្ញុំមិនដឹងដែរ ។

សុវណ្ណៈ ចឹងសព្វថ្ងៃពូកាន់សាសនាអីគេ?

កនៈ កាន់សាសនាព្រះពុទ្ធ ។

សុវណ្ណៈ មូលហេតុអីបានជាពូកាន់សាសនាព្រះពុទ្ធ?

កនៈ ព្រះពុទ្ធបានសងគុណមាតាបីតាទៅ ។

សុវណ្ណៈ ចឹងកាលនៅក្នុងរបបខ្មែរក្រហម ពូគោរពសាសនាយ៉ាងម៉េចដែលកាលហ្នឹង?

កនៈ កាលហ្នឹងអត់មានគោរពណាទេ កាលហ្នឹងច្បាប់កុំម្មុយនីស្តគេរំលាយចោល ដល់ចូលមកឥឡូវនេះធ្វើសមាហរណ៍កម្មវិញ បានគេឲ្យកាន់សាសនាព្រះពុទ្ធ ។

សុវណ្ណៈ ចឹងពូចូលមកនៅភូមិរបស់ពូនេះពីឆ្នាំណាមកដែលពូ?

កនៈ ដឹងឆ្នាំណាទេ កាលឆ្នាំអ៊ុនតាក់មកហ្នឹង ឆ្នាំ៩៣ ។

សុវណ្ណៈ ក្រែងពូនៅអន្លង់វែងមុនសិនតើ?

កនៈ អន្លង់វែង ។

សុវណ្ណៈ ចឹងអន្លង់វែងហើយបានមកទំនប់ដាច់?

កនៈ បាទ ។

សុវណ្ណៈ កាលហ្នឹងនៅក្នុងអំឡុងអ៊ុនតាក់នៅឡើយឬមួយយ៉ាងម៉េច?

កនៈ កាលជំនាន់អ៊ិនតាក់ហ្នឹងឯង ។

សុវណ្ណៈ ម៉េចបានជាពូមកនៅនេះវិញ?

កនៈ នោះថា រកដីនៅ ទៅនោះគេថាដីគេ ទៅនោះគេថាដីគេ ខ្ញុំបកមកនេះវិញមក ។

សុវណ្ណៈ ចឹងមកនៅនេះដំបូងយ៉ាងម៉េចដែរ?

កនៈ មានម៉េច ស្រេចតែព្រៃ ។

សុវណ្ណៈ ចឹងធ្វើម៉េច សុទ្ធតែព្រៃចឹង?

កនៈ មានម៉េច គាស់កាប់ចម្ការទៅ មួយៗកាប់ចម្ការទៅ ។

សុវណ្ណៈ ចឹងមានខ្លាចមីនអីខ្លះទេ?

កនៈ មានធ្វើម៉េច មានគឺមានហើយធ្វើទៅ បើមិនធ្វើបានអីធ្វើ មានគោណាមានកាប់គាស់និងចបហ្នឹង ។

សុវណ្ណៈ ចឹងនៅនេះដីមាននៅឡើយទេ តែគេមិនទាន់ដោះមីនទេ?

កនៈ នៅទេ ។

សុវណ្ណៈ ចឹងយើងធ្វើយ៉ាងម៉េច មានដោះមីនខ្លួនឯងខ្លះទេឬមានមកជួយដោះមីនដែរ?

កនៈ ក្រោយមកឆ្នាំប៉ុន្មានទេ បានពួកស៊ីម៉ាកគេមកដោះនោះ កាលមុនដំបូងមានពីណាដោះឲ្យ កាលហ្នឹងទីងតៀមជាមួយអ៊ុនតាក់នោះ ។

សុវណ្ណៈ ចឹងយើងយ៉ាងម៉េចទៅ បើសិនសុទ្ធតែមីនចឹងយើងហ៊ានមកនៅដែរ?

កនៈ មីនវាមានតាមបន្ទាយគេ កាលមានបន្ទាយគេមានមីន ដីប្រជាពលរដ្ឋគេអត់មានដាក់ទេ សព្វថ្ងៃនៅភូមិអូរឫស្សីខាងស៊ីម៉ាក គេរាវអស់ហើយតើ គេធ្វើភូមិកើត នៅនេះភូមិចាស់ហ្នឹង ។

សុវណ្ណៈ ចឹងអានេះអូរស្វាយចាស់?

កនៈ បាទ ។

សុវណ្ណៈ អូរស្វាយចាស់ហ្នឹងមានមីនច្រើនទេ កាលមកនៅភូមិនេះដំបូង?

កនៈ មាន១៥គ្រួសារ ។

សុវណ្ណៈ តែមានមីននៅសល់ច្រើនទេ នៅតាមដីភូមិហ្នឹង?

កនៈ មាននៅតាមបន្ទាយនៅជើងភ្នំនោះ ។

សុវណ្ណៈ តែមានខាងណាមកជួយដោះមីននៅភូមិនេះទេ កាលហ្នឹង?

កនៈ ពួកស៊ីម៉ាក ។

សុវណ្ណៈ ពេលសមាហរណ៍កម្មហើយបានគេមក?

កនៈ បាទ ។

សុវណ្ណៈ ចឹងមុនសមាហរណ៍កម្មមានខាងណាគេចុះមកជួយដោះទេ?

កនៈ អត់មានទេ អត់មានជួយដោះទេ ធ្វើផ្សងព្រេង ។

សុវណ្ណៈ ចឹងមានខាងទាហានគេមកជួយដោះយើងទេ?

កនៈ អត់មានទេ ។

សុវណ្ណៈ ចឹងប្រជាជនយើងក្នុងភូមិហ្នឹង យើងចេះដោះខ្លួនយើងដែលទេ?

កនៈ អត់ដោះទេ ដូចខ្ញុំថាមិញ ធ្វើផ្សងព្រេង បើកាប់លើមីនក៏ងាប់ទៅ ។

សុវណ្ណៈ ចឹងនៅក្នុងភូមិពូមានអ្នកជាន់មីនអីទេ ពេលចូលមករស់នៅហ្នឹង កាលហ្នឹង?

កនៈ មានជាន់ដែលតើ តានេះ ។

សុវណ្ណៈ ចឹងមានជាន់មីនអីដែរ?

កនៈ បាទ ។

សុវណ្ណៈ ចឹងយើងចូលមកនៅទាំងផ្សងព្រេងទេ?

កនៈ ផ្លូវព្រៃ ។

សុវណ្ណៈ ចឹងកាលហ្នឹងយើងមានហ៊ានទៅណាផ្ទះផ្ទាល់បានទេ?

កនៈ យើងដើរតាមផ្លូវធម្មតា បើក្រៅពីផ្លូវធម្មតា អត់ហ៊ានទេ ។

សុវណ្ណៈ ចឹងយើងចូលមកនៅដំបូងយើងមានការភ័យខ្លាចទេ?

កនៈ ភ័យដែរ ខ្លាចដែរ មិនមែនភ័យតែមីនទេ ភ័យទាំងសត្វខ្លាទៀត ។

សុវណ្ណៈ ចឹងមានសត្វព្រៃទៀត?

កនៈ ហ្នឹងហើយ បើចឹញ្ចឹមជ្រូកឆ្ងាយពីផ្ទះមិនបានហូបទេ ទាល់ធ្វើជិតផ្ទះដុតភ្លើងផងវាយប៉ោតផង បើធ្វើឆ្ងាយពីផ្ទះចប់ ។

សុវណ្ណៈ ចឹងប្រជាជនចុះមកនៅដំបូងភាគច្រើនគេមករកស៊ីអីគេ?

កនៈ មានរកស៊ីអី មានតែដងដំរបោចវល្លិទេ មានធ្វើស្រែប៉ុណ្ណឹង មានចេញចូលណាបានទៅថៃវាឆ្ងាយ ។

សុវណ្ណៈ មានបរបាញ់សត្វអីខ្លះទេ?

កនៈ គ្មានទេ មានកាំភ្លើងបាញ់ កាលនៅច្បាំងកាលហ្នឹងមានកាំភ្លើង ។

សុវណ្ណៈ ចឹងនៅខាងភូមិអីគេមានចុះមកណែនាំយើងពន្យល់អីអត់កាលហ្នឹង កាលពូចូលមកនៅដំបូងហ្នឹង?

កនៈ មានគេមកការមីនហ្នឹងឯង បើខ្ញុំខ្លះចេះតែទៅធ្វើទៅ ។

សុវណ្ណៈ ចឹងពូចូលមកនៅដំបូងគេដាក់ឈ្មោះភូមិអូរស្វាយតែម្តងឬគេដាក់ឈ្មោះតាមលេខកងពល?

កនៈ ហ្នឹងភូមិអូរស្វាយចាស់របស់គេ ។

សុវណ្ណៈ ចឹងភូមិអូរស្វាយចាស់ តាំងពីដើមមកតែម្តង?

កនៈ ហ្នឹងហើយ ។

សុវណ្ណៈ អត់មានភូមិ៨១ភូមិ៨៩អីទេ ភូមិ១០៥អីទេ?

កនៈ អត់ទេ ពួក១០៥គេដាក់ឈ្មោះតាមកងពលគេ ។

សុវណ្ណៈ ចឹងនៅនេះអត់មានដាក់ឈ្មោះតាមកងពលទេ.?

កនៈ អត់ទេ ។

សុវណ្ណៈ ដាក់ឈ្មោះអូរស្វាយ?

កនៈ អូរស្វាយភូមិចាស់កំណើតរបស់គេតែម្តង ។

សុវណ្ណៈ ចឹងម៉េចបានជាពូដឹងថា ជាភូមិចាស់កំណើតមក?

កនៈ ខ្ញុំនៅអូរស្វាយ ។

សុវណ្ណៈ	ចឹងជាភូមិចាស់គេតាំងពីដើមទេ?

កនៈ	បាទ ។

សុវណ្ណៈ	ចឹងក្រោយមកមានរៀបភូមិចាត់ចែងម្តងទៀតទេ ពីឆ្នាំណាមកគេរៀបមានជាភូមិមានជាឃុំជាស្រុកអីមក?

កនៈ	កាលសម័យអ៊ុនតាក់ឆ្នាំ៩៣ ។

សុវណ្ណៈ	ចឹងតាំងពីឆ្នាំ៩៣មកគេរៀបចំមក?

កនៈ	រៀបចំបញ្ជូនកម្លាំងមកពីក្នុង១មក ភូមិនេះគេនិយាយពីដើមមិញ គេនិយាយភូមិចោរ ។

សុវណ្ណៈ	ភូមិនេះគេហៅភូមិចោរ?

កនៈ	បាទ ។

សុវណ្ណៈ	មិញបានគេហៅភូមិចោរ?

កនៈ	ចុះបើចោរលួចគោក្របីពីក្នុងមក មកដាក់ក្នុងភូមិនេះ ភូមិអូរស្វាយនេះ ដល់ពេលស្ងាត់ទៅបញ្ជូនទៅថៃនេះ ។

សុវណ្ណៈ	ចឹងពេលលួចបានយកទៅលក់នៅថៃ?

កនៈ	ហ្នឹង គេទុកនៅភូមិនេះសិន ភូមិអូរស្វាយហ្នឹង ដល់ពេលរៀងស្ងាត់ហើយគេហៅថៃចុះមកយកមក អាហ្នឹងគេដាក់ភូមិអូរស្វាយ តែកាលពីដើមគេហៅភូមិចោរទេ ។

សុវណ្ណៈ	ចឹងផ្លូវអីយើងមានត្រឹមត្រូវទេ?

កនៈ	ផ្លូវដើងទេ ។

សុវណ្ណៈ	ចឹងចង់ធ្វើដំណើរទៅណាក៏ពិបាកដែរ?

កនៈ	ពិបាក មានគោយន្ត មានឡានដូចឥឡូវណា មានត្រឹមរទេះអស់ហើយ ។

សុវណ្ណៈ	ចឹងបទពិសោធន៍ពូផ្ទាល់ ពូធ្លាប់ឆ្លងកាត់សង្គ្រាម ធ្លាប់ឆ្លងកាត់របបខ្មែរក្រហម ធ្លាប់ឆ្លងកាត់របបលន់ នល់ ចឹងពូយល់ឃើញយ៉ាងម៉េចចំពោះបទពិសោធន៍ពូផ្ទាល់ ពូយល់ថាសង្គ្រាមហ្នឹងមានផលប្រយោជន៍ឬគ្មានផលប្រយោជន៍ទេ?

កនៈ	បើមានសង្គ្រាមទៀត ខ្មែរយើងមានតែរលាយ ខ្ញុំមិនចង់បានទេរឿងសង្គ្រាម ខ្ញុំមានពិសោធន៍សង្គ្រាមប៉ុន្មានសិបដងហើយ តាំងពីជំនាន់បារាំង តែបារាំងខ្ញុំមិនបានទាន់ទេ ហើយជំនាន់ លន់ នល បានដាក់ស្តែងផ្ទាល់ សម័យប៉ុល ពត នេះផ្ទាល់ហើយបីជំនាន់ហើយបើថា ធ្វើសង្គ្រាមទៀត មានតែនៅស្លូត មិនមែនប្រជាពលរដ្ឋទេ មានគេអ្នកក្រៅទេ អ្នកក្រៅគ្រាន់តែបញ្ឆេតទេ ដើម្បីឲ្យខ្មែរវាយគ្នាឯង ដូចមាន់គេលាបឲ្យឆ្លងឲ្យជល់គ្នាហ្នឹងអត់មានចំនិញទេ មានតែហិនហោចប្រជាពលរដ្ឋទេ ខ្ញុំមិនចង់មានសង្គ្រាម បើនិយាយពីខ្លួន

ខ្ញុំច្បាំងប៉ុន្មានឆ្នាំហើយ តាំងពីណាមកគ្មានទទួលបានផលប្រយោជន៍ទេ មិនពូពាក្យចាស់ថា អ្នកឡើងបានត្រឹមបេះ អ្នកប្រឡេះបានស៊ីទេ អ្នកឡើងបានត្រឹមស្រមោចស្រអាលខាំដល់ ហើយលទ្ធផលទេ រឿងសង្គ្រាមខ្ញុំមិនចង់បាន ប្រជាជនក្នុងភូមិក៏ចឹងដែរ បើហ៊ានឲ្យធ្វើសង្គ្រាមទៀតមើល បើមិនដេញកាប់អ្នកបង្ករឿងឥឡូវ អត់មានចង់បានទេរឿងសង្គ្រាម សង្គ្រាមយ៉ាប់ណាស់ យ៉ាប់ទាំងប្រពន្ធកូនយ៉ាប់ទាំងចៅ វេទនា បាយមិនត្រង់មាត់ ច្បាំងភ្លីឡើងស្តាប់តែស្នូកាំភ្លើងផ្សែងទេ មិនចង់បានទេ រឿងសង្គ្រាម អ្នកណាចង់បានសង្គ្រាមធ្វើទៅ ខ្ញុំមិនចង់បានទេ អ្នកចង់បានសង្គ្រាមមានតែអ្នកល្ងង់មែនទែនហើយ ។

សុវណ្ណៈ ចឹងពូសព្វថ្ងៃគេមានដាក់ឲ្យរៀនពីរបបខ្មែរក្រហម រៀនអីនៅតាមសាលារៀនពូ គេរៀនឲ្យក្មេងដឹងពូពីរបបខ្មែរក្រហម ពូយល់ឃើញថា ការដាក់បង្រៀនហ្នឹង វាល្អឬមិនល្អទេពូ?

កនៈ និយាយមិនល្អយ៉ាងម៉េច ព្រោះអាហ្នឹងបំបាត់ការកើតមានសង្គ្រាម បំបាត់ការកាប់សម្លាប់ មិនល្អយ៉ាងម៉េច បើយើងយកអ្នកសម្លាប់មកបន្តទៀតវាមិនហិនហោច មិនហិនហោចបរទេសទេ ហិនហោចខ្មែរយើងហ្នឹងណាស់ បទេសចាំតែសើចតើ ក្មួយឯងមិនមើលទូរទស្សន៍ទៅដូចយើងដល់មាន់ដូចអ្នកប្រដាល់រាល់ថ្ងៃហ្នឹងណាស់ មិនមែនអ្នកប្រដាល់បានលុយណា អ្នកអង្គុយក្រៅទេបានលុយនោះ ហើយច្បាំងដូចគ្នា ហើយសព្វថ្ងៃក្មេងៗវាយល់ចឹងឯង តិចយល់ប្រឡុំថា ច្បាំងគ្នាសប្បាយ សប្បាយគេអ្នកធំយើងអ្នកតូចមានបានអី បានត្រឹមម៉ាងាប់ហ្នឹងណាស់ មិនពូខ្ញុំថាទេ អ្នកឡើងបានត្រឹមបេះអ្នកប្រឡេះបានស៊ីដល់ពេលសុខសានត្រានអ្នកបេះដឹង អ្នកល្ងង់នៅតែល្ងង់ដដែល អាហ្នឹងរឿងធ្វើសង្គ្រាមបានត្រឹមមកបញ្ឆោត ។

សុវណ្ណៈ ចឹងសព្វថ្ងៃបើសិនជាគេត្រូវការកូន ត្រូវការពូឲ្យចូលរួមជាមួយទ័ពដើម្បីធ្វើសង្គ្រាមពូទៅចូលរួមជាមួយគេទេ បើស្រុកទេសត្រូវការ?

កនៈ ឈប់ធ្វើ ឈប់ត្រូវការ ។

សុវណ្ណៈ ម៉េចបានជាពូឈប់ធ្វើ?

កនៈ ឈប់ធ្វើហើយបើឆ្អែតហើយ ។

សុវណ្ណៈ ពូម៉េចគិតថាឆ្អែត?

កនៈ ឆ្អែតហើយរឿងសង្គ្រាមធ្វើប៉ុន្មានឆ្នាំមិនឃើញបានអី មិនពូខ្ញុំនិយាយថា អ្នកឡើងបានត្រឹមបេះអ្នកប្រឡេះបានស៊ីទេ អ្នកឡើងមានអីបានត្រឹមអង្រួងខាំ តែអ្នកក្រោមបេះស៊ីទៅយើងគិតត្រឹមប៉ុណ្ណឹងដឹងហើយ ពាក្យចាស់និយាយមិនបេះខុសទេ ពាក្យចាស់ថា ពេលត្រូវការសង្គ្រាមរកអ្នកក្លាហាន អ្នកណាអ្នកក្លាហាន អ្នកក្រហ្នឹងអ្នកក្លាហាន ដល់ស្រុកសានត្រាន

រកអ្នកចេះជិះ ចេះជិះពីណាគេ គិតតែប៉ុណ្ណឹងជិះហើយ អ្នកក្រមានបានធ្វើធំណាទៀត ចប់ហើយ ។

សុវណ្ណៈ ចឹងកាលកូនពូនៅតូចៗពូមានដែលនិយាយប្រវត្តិឆ្លងកាត់របស់ពូទៅប្រាប់កូនៗទេ?

កនៈ ប្រាប់អស់ហើយ ប្រាប់ថាបើធ្វើសង្គ្រាមមានតែខ្ញុំកាប់កូនចោល ។

សុវណ្ណៈ ចឹងច្រើននិយាយរឿងអីគេប្រាប់?

កនៈ ប្រាប់ថាលំបាកយ៉ាងណាស់ វេទនាណាស់ រឿងបាយទឹកមកមិនមែនស្រួលទេ ឆ្លងកាត់ ព្រៃមីន គេធ្វើទំពដាក់មីនហើយ គេរុញកន្ទែងមីនហ្នឹងឯងឲ្យយើងទៅ បើខាងនោះក៏ ទាហានខាងនេះក៏ទាហាន ដាក់ទាំងសងខាងគេឲ្យយើងទៅកន្ទែងមីនមិនងាប់យើង ព្រោះ ខាងនោះគេដាក់មីនដែរ បើទាក់មិនងាប់យើងហើយ ។

សុវណ្ណៈ ខាងណាគេដាក់មីនដែរ?

កនៈ និយាយចឹងក្មួយឯងមិនយល់ទៀតហើយ ដូចក្មួយឯងខាងទាហានរដ្ឋាភិបាលខាងនេះទាហាន ខាងខ្មែរក្រហម ខាងរដ្ឋាភិបាលមករកខ្មែរក្រហមមិនទាក់មីនខ្មែរក្រហម បើខ្មែរក្រហមមក ខាងរដ្ឋាភិបាលមិនទាក់មីនរដ្ឋាភិបាល មិនយល់ទេ ចឹងមិនសងខាងមិនដល់គ្នា ដូចមាន់និង មាន់ដល់គ្នាហ្នឹងណាស់ ប្រឡាក់ធ្យូងដូចគ្នាហ្នឹង សំបុកជាមួយគ្នាទេ ដល់យកមកដល់គ្នាប្រ ឡាកធ្យូងទៅយកមកដល់គ្នាមក ចឹងបានថា រឿងច្បាំងគ្នាកុំប្រឹងចង់បានទេ បើអ្នកណាចង់ បានច្បាំងៗទៅ ។

សុវណ្ណៈ ចឹងសព្វថ្ងៃពូពេញចិត្តនិងរបបរស់នៅក្នុងពេលនេះទេ?

កនៈ បាទ!ខ្ញុំចង់បានដូចពេលនេះ ខ្ញុំមិនចង់បានទៅណាទៀតទេ នៅក៏សប្បាយគ្មានភ័យភិត ខ្ញុំ ចង់និយាយតែប៉ុណ្ណឹងទេ ខ្ញុំមិនត្រូវការច្បាំងអីទេ ខ្ញុំច្បាំងវាឆ្អែតទៅហើយ ។

សុវណ្ណៈ ចឹងពូមានចំណុចណាមិនពេញចិត្តការរស់នៅក្នុងពេលបច្ចុប្បន្ននេះទេ ដែលពូមើលឃើញពូ ឃើញមិនពេញចិត្តចំណុចនេះ មិនពេញចិត្តចំណុចនោះមានទេ?

កនៈ អត់មានទេ រាល់ថ្ងៃមួលម៉ោខ្លួនឯងចាស់ផងហើយឈឺទៀត មិនដឹងជាទៅរកណាលុយអត់ បាន លុយអត់ចាយបាយអត់ស៊ី តែរបបសព្វថ្ងៃពេញរបស់ខ្ញុំហើយ មកពីខ្ញុំចាស់ធ្វើមិន កើត ធ្វើមិនទាន់គេក្មេង ខ្ញុំនិងប្រពន្ធខ្ញុំមួយថ្ងៃកាត់មួយថ្ងៃកោរ កុំដាប់ប្រពន្ធមិនស្រួលខ្លួន ទៅទៀតហើយ ។

សុវណ្ណៈ ចឹងនៅក្នុងភូមិនេះ ប្រជាជនច្រើនជួបផលវិបាកអីខ្លះ នៅក្នុងភូមិពេលបច្ចុប្បន្ននេះប្រជា ជនរស់នៅច្រើនជួបបញ្ហាអីខ្លះ?

កនៈ រឿងពិបាកហ្នឹង គ្រឿងញៀនណែនាំអត់បាន គេធ្វើគ្រឿងញៀនច្រើនពេក ។

សុវណ្ណៈ    មានអីទៀតក្រៅពីក្មេងៗប្រើគ្រឿងញៀន?

កនៈ    មានអីមានរឿងគ្រឿងញៀន  រឿងជីកស៊ីឃាត់មិនស្ដាប់  ឥឡូវធ្វើបារាស់ដើម្បីឃាត់អ្នកដែលបង្ក្រោះម៉ូតូយប់  លួចម៉ូត  ប្រើអំពើហឹង្សាលើក្រុមគ្រួសារ  គេចាប់យកទៅណែនាំដែរ បើមិនចឹងទេ  ទៅជាលួចទៅជាចោរប្លន់ឥឡូវ ។

សុវណ្ណៈ    ចឹងពេលឈឺស្កាត់អី  យើងមានពេទ្យយើងមានមណ្ឌលសុខភាពអីនៅក្នុងភូមិមានទេ?

កនៈ    មាន ។

សុវណ្ណៈ    ចឹងការព្យាបាលអីយ៉ាងម៉េចដែរ?

កនៈ    ព្យាបាលតាមក្បួន  គ្រុញចាញ់ប្រើថ្នាំគ្រុញចាញ់  គ្រុនពោះវៀន  ក្រពះអីហ្នឹង  ប្រើតាមហ្នឹងទៅ  តាមយើងប្រាប់គេ  មានពេទ្យមណ្ឌលគេ ។

សុវណ្ណៈ    ចឹងពេលប្រជាជនឈឺធ្ងន់មែនទែន  នៅមណ្ឌលសុខភាពអាចជួយព្យាបាលយើងបានទេ?

កនៈ    បានទាល់តែបញ្ជូនទៅខាងអន្លង់វែង ។

សុវណ្ណៈ    ចឹងពេលឈឺធ្ងន់នាំទៅអន្លង់វែងទៅ?

កនៈ    បាទ! ទៅពេទ្យរដ្ឋ ។

សុវណ្ណៈ    ចឹងសម្រាប់ខ្លួនពូផ្ទាល់គិតថារបបខ្មែរក្រហមយ៉ាងម៉េចដែរ?

កនៈ    របបខ្មែរក្រហមពីណាចង់បានកម្មហើយ        ព្រាត់ប្រាស់បែកបាក់បងប្អូនប្រពន្ធកូនដូចខ្ញុំនិយាយមិញហ្នឹង  មិនល្អជាទេ  បងប្អូនមិនស្គាល់បងប្អូនម៉ែក៏មិនស្គាល់ម៉ែ  មិនចង់បានទេ ។

សុវណ្ណៈ    ចឹងពូមានយោបល់អីចង់បន្ថែម  មានអីដែលខ្ញុំមិនបានសួរពូមានទេ?

កនៈ    អត់មានទេ  មានតែប៉ុណ្ណឹងឯង ។

សុវណ្ណៈ    ចឹងខ្ញុំអរគុណពូច្រើន  ដែលបានផ្ដល់បទសម្ភាសឲ្យខាងខ្ញុំពូ ។

កនៈ    បាទ ។

**ចប់**